ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់ អគ្គនាយកដ្ឋានពន្ធដារ

PATENT TAX COLLECTION PROCESS THE GENERAL DEPARTMENT OF TAXATION

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់ អគ្គនាយកដ្ឋានពន្ធដារ

PATENT TAX COLLECTION PROCESS THE GENERAL DEPARTMENT OF TAXATION

**គ្រូណែនាំ៖ វ៉ាន់ ស្រីនាង**

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទៈ ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

វ៉ាន់ ស្រីនាង

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថា ជំនាញគណនេយ្យគឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវការយល់ដឹងពីការបង់ពន្ធដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យអនុវត្ត និងពន្ធ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយរហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តន៍ការងារ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្តន៍ ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមនាងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមនាងខ្ញុំបានសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ យល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃដំណើរការនៃការប្រមូលពន្ធប៉ាតង់។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀត ដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមនាងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀត កាន់តែមានភាពល្អប្រសើរ។

# រចនាសម្ព័ន្ធ



**ស៊ុន ចិន្តា**
ID: B22/236



**ស៊ុំ ចន្ទេ**
ID: B22/2585



**អ៊ឹន វឌ្ឍនា**
ID: B22/793



**ទុយ ស្រីលីន**
ID: B22/301



**ម៉ៅ ស្រីលីម**
ID: B22/2440

# សេចក្តីថ្លែងអំណរគុណ

ក្រុមនាងខ្ញុំ ជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **វ៉ាន់ ស្រីនាង** ជាគ្រូណែនាំ ដែលបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដា ទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ...ចន្ទ...៦កើត... ខែ...កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី...២៧... ខែ...តុលា... ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

ស៊ុន ចិន្តា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

អគ្គនាយកដ្ឋានពន្ធដារគឺដំដៅទៅដល់ មិនត្រឹមតែជាស្ថាប័នរដ្ឋមួយដែលអាចជួយរកចំណូលដល់ជាតិនោះទេ ប៉ុន្តែ ស្ថាប័ននេះ ថែមទាំងជាស្ថាប័នមួយដែលបានជួយក្នុងការគ្រប់គ្រងទៅលើម្ចាស់អាជីវកម្ម សហគ្រាស ស្ថាប័នរដ្ឋ ឯកជន អង្គការ ម្ចាស់អាជីវកម្ម ក្រុមហ៊ុននានា ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ទៅតាមបទប្បញ្ញត្តិរបស់អគ្គនាយកដ្ឋានពន្ធដារដែលបានកំណត់។ អគ្គនាយកដ្ឋានពន្ធដារ បានចាប់ផ្តើមដំណើរការតាំងពីឆ្នាំ១៩៥៣ មកទល់នឹងពេលបច្ចុប្បន្ននេះ សង្កេតឃើញថា ការប្រតិបត្តិការទៅលើការអនុវត្តន៍ច្បាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ពិតជាមានប្រសិទ្ធភាពខ្ពស់។

ឈរលើមូលដ្ឋានមួយដែលជាកត្តានៅក្នុងការស្រាវជ្រាវ និងចងក្រងសារណាមួយនេះឡើង គឺស្វែងយល់អំពីចំណុចសំខាន់ៗនៃ"**ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**"នៅក្នុងដំណើរការនេះផងដែរ អគ្គនាយកដ្ឋានពន្ធដារបាន កំណត់កាលបរិច្ឆេទ កម្រិតអត្រាពន្ធ មធ្យោបាយនៃការបង់ពន្ធប៉ាតង់យ៉ាងច្បាស់ ជូនទៅដល់អ្នកជាប់ពន្ធគ្រប់រូបក្នុងការអនុវត្តន៍តាម។ អគ្គនាយកដ្ឋានពន្ធដារថែមទាំងបានសហការជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងការងារ និងក្រសួងផ្សេងៗទៀតក្នុងការសម្រេចបាននូវការអនុវត្តន៍យ៉ាងតឹងរឹងមួយនេះ ។

ក្រោយពីបានបញ្ចប់ការងារស្រាវជ្រាវទៅលើប្រធានបទមួយនេះរួចមក បានធ្វើឱ្យក្រុមនាងខ្ញុំយល់កាន់តែច្បាស់អំពីច្បាប់ស្តីពី សារពើពន្ធរបស់អ្នកជាប់ពន្ធ និងសាធារណៈជន ព្រមទាំងការអនុវត្តន៍ការងារប្រមូលពន្ធប៉ាតង់របស់រដ្ឋបាលសារពើពន្ធនៃអគ្គនាយកដ្ឋានពន្ធដារយ៉ាងម៉ត់ចត់និងប្រកបទៅដោយប្រសិទ្ធិភាពខ្ពស់។ បន្ទាប់ពីបានធ្វើកិច្ចការស្រាវជ្រាវដែលទាក់ទងទៅនឹងប្រធានបទស្តីពី នៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដាររួចមក យើងខ្ញុំសង្កេតឃើញថា មានការរឹតបន្តឹងយ៉ាងហ្មត់ចត់ទៅលើការអនុវត្តន៍ច្បាប់ពន្ធប៉ាតង់ទៅលើអ្នកជាប់ពន្ធនានា ដែលបានប្រកបរបររកស៊ីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ។ រាល់មន្ត្រីគ្រប់ផ្នែកទាំងអស់របស់អគ្គនាយកដ្ឋានពន្ធដារសុទ្ធសឹងតែមានជំនាញ ទេពកោសល្យ សមត្ថភាព និងចំណេះដឹង ក្នុងការបំពេញ និងអនុលោមតាមការងារដែលអាចផ្តល់ទំនុកចិត្ត និងធានាបាននូវគុណភាពជូនទៅសាធារណៈជន និងអ្នកជាប់ពន្ធផងដែរ។ តាមរយៈអ្នកជាប់ពន្ធទាំងអស់ដែលគោរពតាមច្បាប់ពន្ធដែលធានាបានថា ការបង់ពន្ធគឺស្របទៅតាមពេលវេលាកំណត់។ ការបង់ពន្ធរបស់ប្រជាពលរដ្ឋ គឺមានសារៈសំខាន់ណាស់ ព្រោះវាជាប្រភពចំណូលមួយផ្នែកធំក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន។ យ៉ាងណាមិញក៏អាចឱ្យយើងសង្កេតឃើញថា ចំណូលដែលបានមកពីការប្រមូលប៉ាតង់ ជាចំណូលមួយយ៉ាងសំខាន់ ក្នុងចំណោមចំណូលផ្សេងៗទៀត ដែលបានធ្វើឱ្យប្រទេសកម្ពុជាឈានទៅមុខជាលំដាប់។

ជារួមមក ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារត្រូវបានអនុវត្ត និងប្រព្រឹត្តទៅតាមច្បាប់ ដោយបានចាត់ចែងយ៉ាងច្បាស់លាស់ រួមទាំងប្រកបទៅដោយតម្លាភាព ប្រសិទ្ធិភាព វិជ្ជាជីវៈ និងសីលធម៌យ៉ាងគួរឱ្យជឿជាក់ទុកចិត្ត។

# មាតិកា

ទំព័រ

អារម្ភកថា .......... i

រចនាសម្ព័ន្ធ .......... ii

សេចក្តីថ្លែងអំណរគុណ .......... iii

អំណះអំណាង .......... iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ .......... v

មាតិកា .......... vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ.......... ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ.......... ២

១.តើដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារមានលក្ខណៈដូចម្តេច?

២.តើការប្រមូលពន្ធប៉ាតង់បានផ្តល់ប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ?

១.៣ គោលបំណងនៃការស្រាវជ្រាវ.......... ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.......... ២

១.៤.១ ទំហំដែនកំណត់ .......... ២

១.៤.២ វិសាលភាព.......... ២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ.......... ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ.......... ២

១.៥.១ ការប្រមូលទិន្នន័យតាមបែបគុណវិស័យ.......... ២

១.៥.២ វិធីសាស្ត្រវិភាគទិន្នន័យ.......... ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ.......... ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......... ៤

## ជំពូកទី២
## រំលឹកទ្រឹស្តី

២.១ លក្ខណៈទូទៅនៃ

២.១.១ និយមន័យ.......... ៥

២.១.២ ប្រវត្តិរបស់ពន្ធ.......... ៥

២.១.៣ ទ្រឹស្តីពាក់ព័ន្ធនឹងពន្ធ........ ៦
២.២ ដំណើរការនៃការប្រមូលពន្ធ........ ៦
២.២.១ និយមន័យ........ ៦
២.២.២ ដំណើរការនៃការប្រមូលពន្ធ........ ៦
២.២.៣ ទ្រឹស្តីប្រមូលពន្ធ........ ៧
២.៣ ផលប្រយោជន៍នៃការប្រមូលពន្ធដល់សង្គមជាតិ........ ៧
២.៣.១ និយមន័យ........ ៧
២.៣.២ ប្រវត្តិនៃការបង់ពន្ធ........ ៧
២.៣.៣ ទ្រឹស្តី........ ៩

## ជំពូកទី៣
## ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ

៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ........ ១០
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ........ ១០
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ........ ១១
ក.ចក្ខុវិស័យ........ ១១
ខ.បេសកកម្ម........ ១២
គ.គោលដៅ........ ១៣
ឃ.គុណតម្លៃ........ ១៣
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច........ ១៤
ក. រចនាសម្ព័ន្ធគ្រប់គ្រង........ ១៤
ខ. តួនាទីនិងភារៈកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ........ ១៦
៣.១.៤ និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ........ ១៧
៣.២ ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ........ ១៨
៣.២.១.មូលហេតុនៃការប្រមូលពន្ធប៉ាតង់........ ១៨
៣.២.២.ដំណើរការនៃការប្រមូលពន្ធ........ ១៨
៣.២.៣.នីតិវិធីនិងក្រុមហ៊ុនដែលត្រូវចុះបញ្ជីពន្ធប៉ាតង់........ ២១
៣.២.៤ .បែបបទនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ........ ២២
៣.២.៥.ការឈប់ផ្អាកនិងផ្លាស់ប្តូរម្ចាស់អាជីវកម្ម........ ២៦
៣.៣ ផលប្រយោជន៍ដែលទទួលបានពីការបង់ពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ........ ២៧
៣.៣.១.អត្ថប្រយោជន៍ដែលទទួលបានពីការបង់ពន្ធប៉ាតង់ចំពោះសង្គមជាតិ........ ២៧
៣.៣.២.ហានិភ័យនៃការមិនបង់ពន្ធប៉ាតង់........ ២៨

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង........................................................................................ ៣០
៤.២ ការវិភាគលើចំណុចខ្សោយ...................................................................................... ៣១

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន.................................................................................................. ៣៣
៥.២ ការផ្តល់អនុសាសន៍............................................................................................... ៣៣

**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ៖

នៅក្នុងសង្គមជាតិយើងសព្វថ្ងៃ ការធ្វើអាជីវកម្ម គឺមានការកើនឡើងយ៉ាងច្រើន ពីមួយឆ្នាំទៅមួយឆ្នាំ ដោយមានការចូលរួមពីវិនិយោគិនទាំងជនជាតិខ្មែរ និងបរទេស។ ទន្ទឹមនឹងនេះដែរ ដើម្បីជួយឱ្យប្រទេសកម្ពុជាកែប្រែផ្លាស់មុខមាត់ថ្មី ពីប្រទេសកំពុងអភិវឌ្ឍឱ្យក្លាយជាប្រទេសអភិវឌ្ឍ អគ្គនាយកដ្ឋានពន្ធដារបានធ្វើការរៀបចំគោលនយោបាយសាជីវកម្មទាំងអស់ ដើម្បីដកហូតពន្ធ។ ដូចដែលបានដឹងហើយថា ពន្ធគឺ ជាចំណូលរបស់រដ្ឋ។ ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលស្ថិតនៅឧបទ្វីបឥណ្ឌូចិនដែលបច្ចុប្បន្នកំពុងមានការអភិវឌ្ឍយ៉ាងខ្លាំងស្ទើរគ្រប់វិស័យ។ នៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជាឱ្យមានការផ្លាស់ប្តូរនូវមុខមាត់ថ្មីបែបនេះ ក៏មានការរួមចំណែកដែរពីប្រជាពលរដ្ឋ និងបណ្ដាក្រុមហ៊ុនផ្សេងៗ ដែលកំពុងធ្វើសកម្មភាពដកហូតពន្ធពីអ្នកប្រើប្រាស់ចុងក្រោយយកទៅបង់ជូនរដ្ឋ ដើម្បីយកទៅផ្គត់ផ្គង់ការចំណាយរបស់រាជរដ្ឋាភិបាល និងអភិវឌ្ឍផ្នែកផ្សេងៗទៀតនៅក្នុងប្រទេសឱ្យកាន់តែបន្តរីកចម្រើនទៅមុខទៀត។ ចំពោះដំណើរការនៃច្បាប់ស្តីពីការប្រមូលពន្ធពីប្រជាពលរដ្ឋ ត្រូវបានធ្វើការសម្រេចចិត្តបង្កើតឡើង ដោយក្រុមប្រឹក្សាបដិវត្តន៍កម្ពុជាដែលមានឈ្មោះថា អគ្គនាយកដ្ឋានពន្ធដារ តាមសេចក្តីសម្រេចលេខ៤១ សរ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៨១។

ជាការពិតណាស់ ការបង់ពន្ធ វាគឺជាការចូលរួមចំណែកក្នុងថវិការជាតិ ដើម្បីឱ្យរដ្ឋមានលុយយកទៅចំណាយដោយមិនចាំបាច់បោះពុម្ពលុយបន្ថែម ដែលអាចបង្កឱ្យមានបញ្ហាអតិផរណា។ សម្រាប់កម្ពុជា ការបង្កើនចំណូលពីការបង់ពន្ធគឺជាគន្លឹះដ៏សំខាន់មួយដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេស។ បច្ចុប្បន្នប្រទេសកម្ពុជាមានប្រភេទពន្ធអាករច្រើនប្រភេទ រួមមាន ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ពន្ធប៉ាតង់ និងប្រភេទពន្ធផ្សេងៗជាច្រើនទៀត ហើយចំពោះការប្រមូលពន្ធប៉ាតង់ មានការបែងចែកការប្រមូលពន្ធទៅតាមខេត្ត ខណ្ឌនីមួយៗទៅតាមប្រភេទអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ ពន្ធប៉ាតង់ គឺបានចូលរួមចំណែកក្នុងការប្រមូលប្រាក់ពន្ធទៅតាមទំហំរបស់បណ្ដាអាជីវកម្ម ដែលមានផែនការណែនាំកិច្ចការប្រកបអាជីវកម្មឱ្យស្របទៅតាមទិសដៅអភិវឌ្ឍនៃសេដ្ឋកិច្ចជាតិ ដែលបានរួមចំណែកបង្កើនចំណូលថវិការរដ្ឋ ដើម្បីបម្រើនូវសំណូមពរពីការចំណាយក្នុងការអភិវឌ្ឍប្រទេស។

ក្នុងនោះផងដែរ ដើម្បីឱ្យមានភាពងាយស្រួលដល់ការប្រកបអាជីកម្មទាំងអស់ អគ្គនាយកដ្ឋានពន្ធដារក៏បានរៀបចំបង្កើតឡើងនូវសាខាយ៉ាងច្រើនទូទាំងប្រទេស ដើម្បីឱ្យក្រុមហ៊ុនប្រកបអាជីវកម្មទាំងអស់ដែលបានជាបុគ្គលជាប់ពន្ធមានភាពងាយស្រួលក្នុងការបង់ពន្ធជូនរាជរដ្ឋាភិបាល ហើយការបង់ពន្ធនេះក៏បានចូលរួមនូវចំណែកយ៉ាងច្រើន ក្នុងការជួយកសាងសេដ្ឋកិច្ចជាតិគេហដ្ឋានរចនាសម្ព័ន្ធឱ្យមានរបៀបរៀបរយយ៉ាងល្អ និងមានសណ្ដាប់ធ្នាប់ល្អក្នុងសង្គម។ ពន្ធ គឺជាប្រភពចំណូល ដ៏ធំមួយរបស់រដ្ឋាភិបាលលើសេវាសាធារណៈនានាដូចជា មន្ទីពេទ្យ ផ្លូវថ្នល់ ព្រំដែន និងការការពារបេតិកភ័ណ្ឌជាតិ ការបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល ការសាងសង់ស្ពាន សាលារៀន និងការចូលរួមចំណែកក្នុងថវិកាជាតិ ដើម្បីឱ្យរដ្ឋមានប្រាក់យកទៅចំណាយ ដោយមិនចាំបាច់បោះពុម្ពក្រដាសប្រាក់បន្ថែម ដែលអាចបង្កឱ្យមានបញ្ហាអតិផរណា។ សម្រាប់

កម្ពុជា ការបង្កើនចំណូលពីការបង់ពន្ធ គឺជាគន្លឹះដ៏សំខាន់មួយ ដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេស។

កត្តាទាំងអស់នេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទពន្ធដារមួយមកធ្វើសិក្សាស្រាវជ្រាវ ដើម្បីជាចំណេះដឹង និងស្វែងយល់បន្ថែមទៀត អំពីដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ៖

ដើម្បីឱ្យការប្រមូលពន្ធមានប្រសិទ្ធភាព អគ្គនាយកដ្ឋានពន្ធដារក៏បានបង្កើតច្បាប់មួយចំនួន ស្តីពីការបង់ពន្ធ ដើម្បីជៀសវាងកុំឱ្យម្ចាស់អាជីវកម្មមួយចំនួនគេចវេស ឬសុំពន្យាពេលក្នុងការបង់ពន្ធជូនរាជរដ្ឋាភិបាល។ ដោយយល់យ៉ាងនេះហើយ ទើបក្រុមយើងខ្ញុំបានយកសំណួរមួយចំនួនមកធ្វើការចោទសួរដូចជា ៖

១.តើដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារមានលក្ខណៈដូចម្តេច?

២.តើការប្រមូលពន្ធប៉ាតង់បានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ ៖

គោលបំណងក្នុងការស្រាវជ្រាវទៅលើប្រធានបទនេះគឺដើម្បីស្វែងយល់បន្ថែមអំពី

- ដើម្បីយល់ដឹងអំពីដំណើរការនៃការប្រមូលពន្ធប៉ាតង់
- យល់ដឹងអំពីទិដ្ឋភាពទូទៅនិងប្រវត្តិរបស់ស្ថាប័ន
- ស្វែងយល់ពីផលប្រយោជន៍នៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ
- ស្វែងយល់ពីទស្សនៈវិស័យ បេសកកម្មរបស់អគ្គនាយកដ្ឋានដារ។

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ៖

### ១.៤.១ ទំហំ ដែនកំណត់

ការស្រាវជ្រាវនេះ គឺសិក្សាពីដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់ពន្ធដារ និងច្បាប់មួយចំនួនដែលទាក់ទងនឹងប្រភេទពន្ធប៉ាតង់ និងអត្ថប្រយោជន៍នៃការដកហូតពន្ធប៉ាតង់ក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ប្រធានបទនេះគ្របដណ្តប់ទៅលើការគ្រប់គ្រង ការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ។

### ១.៤.២ វិសាលភាព

តាមការស្រាវជ្រាវនៃប្រធានបទខាងលើគឺប្រសិនបើយើងលើកយកចំណុចដែលទាក់ទងទៅនឹងទំហំ និងដែនកំណត់នៃពន្ធនោះ គឺមានន័យទូលំទូលាយណាស់ ហើយក៏មានច្រើនប្រភេទ ច្រើនសណ្ឋានផងដែរ ដូច្នេះហើយ តម្រូវឱ្យជ្រើសរើសយកពន្ធមួយ មកធ្វើការសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។ នៅត្រង់ចំណុចនេះដែរ យើងនឹងលើកយកពន្ធមួយប្រភេទគឺ ពន្ធប៉ាតង់នៅឆ្នាំ២០២១ មកធ្វើការបកស្រាយឱ្យកាន់តែច្បាស់លាស់ថែមមួយកម្រិតទៀត ដើម្បីឱ្យបណ្តាអាជីវករ ឬម្ចាស់ក្រុមហ៊ុនទាំងអស់បានដឹងថា តើខ្លួនជាប់ពន្ធប៉ាតង់នៅពេលណា និងក្នុងកម្រិតណា។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាស្រាវជ្រាវរបាយការណ៍ស្តីពីការគ្រប់គ្រងទៅលើ "ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ" ក្រុមយើងខ្ញុំបានប្រមូលទិន្នន័យតាមវិធីសាស្ត្រដូចខាងក្រោម៖

### ១.៥.១ ការប្រមូលទិន្នន័យតាមបែបគុណវិស័យ

ការស្រាវជ្រាវនេះ គឺប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យតាមបែបគុណវិស័យ ដែលជាវិធីសាស្ត្រស្រាវជ្រាវក្នុងការប្រមូលឯកសារ និងទិន្នន័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ តាមរយៈគេហទំព័រដូចជា ច្បាប់ស្តីពីសារពើពន្ធ(២០២៣) ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកសារក្នុងសៀវភៅគណនេយ្យអនុវត្តន៍ និងពន្ធរបស់សាកលវិទ្យាល័យ វ៉ាន់ដា។

សម្រាប់សំណួរទី១ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ។ ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់ដូចជា សៀវភៅច្បាប់ពន្ធដារកម្ពុជានៃសាកលវិទ្យាល័យវ៉ាន់ដា និងស្រាវជ្រាវតាមរយៈគេហទំព័រ ច្បាប់ស្តីពីសារពើពន្ធ (២០២៣) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីយល់ដឹងអំពីនីតិវិធីក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ។

សម្រាប់សំណួរទី២ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ។ ការស្រាវជ្រាវនេះធ្វើឡើងតាម រយៈការដកស្រង់ទិន្នន័យពីច្បាប់ស្តីពី សារពើពន្ធ (២០២៣) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីយល់ដឹងពីផលប្រយោជន៍នៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន។

**១.៥.២ វិធីសាស្ត្រវិភាគទិន្នន័យ**

ដើម្បីឱ្យការស្រាវជ្រាវនេះទទួលបាននូវចំណុចល្អៗនិងច្បាស់លាស់ដែលអគ្គនាយកដ្ឋានពន្ធដារបាន កំណត់និងបំពេញនូវចំណុចមួយចំនួនដែលមានការខ្វះខាតយើងខ្ញុំបានធ្វើការស្រាវជ្រាវដូចតទៅ ៖

១. ទិន្នន័យចម្បង (Primary Data)

ធ្វើការសាកសួរពីសាស្ត្រាចារ្យទាក់ទងនឹងពន្ធប៉ាតង់ នៅក្នុងសាកលវិទ្យាវ៉ាន់ដា

តាមចំណេះដឹងផ្ទាល់ខ្លួនដែលបានសិក្សាកន្លងមក។

២.ទិន្នន័យបន្ទាប់បន្សំ(Secondary Data)

តាមប្រព័ន្ធអ៊ីនធើណេត (Internet System)

ជាពិសេសតាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារផ្ទាល់

(www.tax.gov.kh)

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ៖

ការស្រាវជ្រាវ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់និស្សិតធ្វើការសិក្សាស្វែងយល់បន្ថែម ដែលជាចំណេះដឹងមួយដ៏សំខាន់ដែលផ្សារភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង ក្នុងការជួយពង្រឹងសមត្ថភាពនៃការយល់ដឹង អំពីដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ។

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះ បានផ្តល់ផលប្រយោជន៍ដូចជា៖

- ❖ ចំពោះនិស្សិតចុះកម្មសិក្សាផ្ទាល់
    - ផ្តល់នូវការយល់ដឹងកាន់តែស៊ីជម្រៅអំពីពន្ធដារបន្ថែមទៀត
    - ទទួលបានបទពិសោធន៍ក្នុងការស្រាវជ្រាវ និងដោះស្រាយបញ្ហាជាក្រុម
    - យល់ដឹងពីដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ
    - ទទួលបានចំណេះដឹងផ្ទាល់ពីការចែករំលែករបស់មន្ត្រីពន្ធដារ
    - ទទួលបាននូវចម្លើយជាក់លាក់
- ❖ ចំពោះនិស្សិត

- បង្កើននូវការយល់ដឹងពីការស្រាវជ្រាវ បណ្តុះចំណេះដឹងថ្មីៗ រួមទាំងការស្វ័យសិក្សា
- ទទួលបាននូវចំណេះដឹងដែលទទួលបានមកពីសារណារបស់រៀមច្បងមកសិក្សាបន្ថែម

❖ ចំពោះសង្គមជាតិ

- ធ្វើឲអគ្គនាយកដ្ឋានពន្ធដាទទួលបានចំណូលបន្ថែមសម្រាប់ជូនរដ្ឋ
- បើកប្រាក់បៀវត្សជូនមន្រ្តីរាជការ គ្រូបង្រៀន គ្រូពេទ្យ មន្រ្តីកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និវត្តន៍ជន និងការសាងសង់ធុរកិច្ច។
- ពន្ធប៉ាតង់អាចជួយឱ្យមានការអភិវឌ្ឍផ្សេងៗក្នុងសេដ្ឋកិច្ចពាក់ព័ន្ធនិង ឧស្សាហកម្ម កសិកម្ម ដោយប្រើប្រាស់សេវាកម្មប៉ាតង់ក្នុងការចំណាយ ឬផលិតផល។
- ការប្រមូលពន្ធប៉ាតង់អាចជួយសម្រួលការប្រើប្រាស់ធនធានធម្មជាតិ ឬស្រទាប់ធនធានក្នុងប្រទេសដោយទាមទារដើម្បីប្រើប្រាស់ធនធានក្នុងវិស័យដែលមានការសន្និដ្ឋានជាសាធារណៈ។
- ពន្ធប៉ាតង់ អាចធ្វើឱ្យមានការរក្សាការប្រកួតប្រជែងសេដ្ឋកិច្ចក្នុងប្រទេស និងការពារអាជីវកម្មក្នុងប្រទេសមិនឱ្យមានការប្រកួតចេញពីពាណិជ្ជកម្មក្រៅប្រទេស។
- ប្រាក់ពន្ធនេះក៏បានជួយសម្រួលដល់ការចំណាយផ្សេងៗរបស់រដ្ឋ ហើយរដ្ឋក៏បានផ្តល់ប្រាក់ពន្ធនេះទៅដល់ថវិកាជាតិ និងថ្នាក់ក្រោមជាតិជាច្រើនដែរ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ជំពូកដូចខាងក្រោម៖

- **ជំពូកទី១ សេចក្តីផ្តើម** ៖ បង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ( លក្ខណៈទូទៅ លក្ខណៈពិសេស និងលើកឡើងពីដំណោះស្រាយនៃប្រធានបទ )។
- **ជំពូកទី២ រំលឹកទ្រឹស្តី** ៖ បង្ហាញពីនិយមន័យ ប្រវត្តិ និងទ្រឹស្តីដែលពាក់ព័ន្ធនឹងប្រធានបទ។
- **ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ** ៖ បង្ហាញពីស្ថានភាពទូទៅនៃប្រធាន និងការស្រាវជ្រាវដែលសម្រេចបាន។
- **ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** ៖ បង្ហាញពីការវិភាគចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងជំពូកទី៣ដែលបានស្រាវជ្រាវមក។
- **ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** ៖ បង្ហាញពីការសន្និដ្ឋានឱ្យគ្រប់ជ្រុងជ្រោយ ទាំងចំណុចខ្លាំង និងចំណុចខ្សោយ និងថែមទាំងផ្តល់អនុសាសន៍ទៅលើចំណុចខ្សោយផងដែរ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១ លក្ខណៈទូទៅនៃពន្ធ

### ២.១.១ និយមន័យ

- **ពន្ធ** គឺជាកាតព្វកិច្ចបង់ជាប្រាក់ ឬវត្ថុរបស់អ្នកជាប់ពន្ធទៅរដ្ឋាភិបាល ហើយអ្នកជាប់ពន្ធទាំងនោះទទួលតម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ និងសេវាសាធារណៈ[1]។

- **ពន្ធ** គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធ[2]។

- **ពន្ធ** គឺជាកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប ក្នុងការបង់ជាប្រាក់ ឬទំនិញទៅឱ្យរដ្ឋដោយស្ម័គ្រចិត្ត។ ដើម្បីថែរក្សានូវផលប្រយោជន៍សាធារណៈទាំងនោះ ចាំបាច់ត្រូវទាមទារឱ្យមានការចូលរួមពីសំណាក់មហាជន។

- **ពន្ធ** ជារូបភាពមួយនៃការបែងចែកឡើងវិញនូវចំណូលជាតិ ដែលរដ្ឋបានប្រើប្រាស់ ដើម្បីរចនាមួយផ្នែកចំណូលនៃបណ្តាអង្គការចាត់តាំងសេដ្ឋកិច្ចរបស់ពលរដ្ឋ ដើម្បីបម្រើតម្រូវការរួមដល់អង្គភាពទាំងមូល។ ពន្ធមានលក្ខណៈបង្ខំ ហើយមិនសងវិញដោយផ្ទាល់ ប៉ុន្តែបានសងវិញដោយប្រយោលតាមមាគ៌ាផ្សេងៗគ្នា[3]។

- **ពន្ធ** ជាបន្ទុកអ្នកជាប់ពន្ធចំពោះរដ្ឋ និងកាតព្វកិច្ចរបស់គ្រប់សមាសភាពដោយច្បាប់[4]។

### ២.១.២ ប្រវត្តិរបស់ពន្ធ

ពន្ធដំបូង ត្រូវបានកំណត់ទៅលើប្រទេសអេហ្ស៊ីប។ នៅសម័យដើមនៃសាធារណៈរដ្ឋរ៉ូម៉ាំង ពន្ធសាធារណៈមានការវាយតម្លៃតិចតួចលើទ្រព្យសម្បត្តិ និងទ្រព្យដែលជាកម្មសិទ្ធ។ អត្រាពន្ធធម្មតា១% ហើយពេលខ្លះឡើងដល់៣% ករណីមានសង្គ្រាម។ ពន្ធតិចតួចទាំងនោះត្រូវបានគេយកទៅធ្វើដីធ្លី ផ្ទះ និងអចលនទ្រព្យផ្សេងទៀត មានដូចជា ទាសករ សត្វ របស់របរផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិរូបិយវត្ថុ។ មនុស្សម្នាក់មានទ្រព្យកាន់តែច្រើន ជាប់ពន្ធកាន់តែច្រើន ។ ទ្រព្យត្រូវបានប្រមូលពីបុគ្គលម្នាក់ៗ។

ប្រទេសកម្ពុជា រដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ១៩៩៣។ ព្រះអង្គម្ចាស់នរោត្តមសីហនុ ត្រូវបានឡើងសោយរាជ្យបន្ត ដែលការតែងតាំងដំបូងបង្អស់លើព្រះអង្គក្នុងឆ្នាំ១៩៤១។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៣ បន្ទាប់មកត្រូវបានលុបបំបាត់ចោលនៅឆ្នាំ១៩៧៥-១៩៧៩ ដោយសារសង្គ្រាម(របបប៉ុលពត)។ ប្រព័ន្ធពន្ធដារ ត្រូវបានបង្កើតឡើងដំណាក់កាលដំបូងនៅឆ្នាំ១៩៨០ ដោយបានអនុវត្តនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀត។ លើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារ ក៏បានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីអនុវត្ត និងមានការបែងចែកច្បាប់ ព្រមទាំងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកលើមាត្រា៤ នៃច្បាប់សារពើពន្ធបានបង្កើតនូវរបបកំណត់ពន្ធជា៣ប្រភេទ របបពិត របបម៉ៅការ និងរូបបំព្រួញដែលមានចែងជាច់ដោយឡែក។ ប៉ុន្តែនៅពេលបច្ចុប្បន្ន ប្រទេសកម្ពុជា យើងមានរបបពិត តែមួយប៉ុណ្ណោះ[5]។

---

[1] មូលដ្ឋាននៃច្បាប់ស្តីពីសារពើពន្ធ: *ប្រើដោយព្រះរាជក្រមលេខ នស/រមក/០២៩៧/០៣* ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[2] មូលដ្ឋាននៃច្បាប់ស្តីពីសារពើពន្ធ: *ប្រើដោយព្រះរាជក្រមលេខ នស/រមក/០២៩៧/០៣* ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[3] មូលដ្ឋាននៃច្បាប់ស្តីពីសារពើពន្ធ: *ប្រើដោយព្រះរាជក្រមលេខ នស/រមក/០២៩៧/០៣* ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[4] សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២១ បោះពុម្ពថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០២៤ ក្នុងបណ្ណាល័យ*សាកលវិទ្យាល័យវ៉ាន់ដា*

[5] *អគ្គនាយកដ្ឋានពន្ធដារ*, https://www.tax.gov.kh បោះពុម្ពឆ្នាំ ២០១០

**២.១.៣ ទ្រឹស្តីពាក់ព័ន្ធនឹងពន្ធ**

ពន្ធត្រូវបានកកើតឡើង និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ចាប់តាំងពីសង្គមមនុស្ស ចេះរស់នៅប្រមូលផ្តុំគ្នាជាក្រុមរហូតមានការកើតឡើងនៃរដ្ឋាភិបាល ដើម្បីគ្រប់គ្រងរចនាសម្ព័ន្ធនៃប្រទេសជាតិមួយក្នុងគោលបំណងចូលរួមចំណែកការពារនិងអភិវឌ្ឍមាតុភូមិ។ ពន្ធក៏ជាចំណូលសាធារណៈដែលរដ្ឋប្រមូលពីប្រជាពលរដ្ឋ និងសហគ្រាសដើម្បីជួយអភិវឌ្ឍប្រទេស និងផ្តល់សេវាសាធារណៈ។ ម្យ៉ាងវិញទៀត ក៏ជាច្បាប់ឬកិច្ចធម្មនុញ្ញដែលរាជរដ្ឋាភិបាលឬអាជ្ញាធររដ្ឋទាមទាឱ្យបុគ្គល ឬស្ថាប័នបង់ប្រាក់ចូលក្នុងថវិកាជាតិ ដោយគ្មានការប្តូរប្រយោជន៍ដោយផ្ទាល់ នៅក្នុងពេលតែមួយ។ ពន្ធត្រូវបានប្រមូលដើម្បីធ្វើឱ្យរដ្ឋអាចអនុវត្តភារកិច្ចសាធារណៈដូចជា សេវាសុខាភិបាល ការអប់រំ សន្តិសុខ បរិស្ថាន សាធារណៈនិងអភិវឌ្ឍសេដ្ឋកិច្ច។

## ២.២ ដំណើរការនៃការប្រមូលពន្ធ

**២.២.១.និយមន័យ**

ដំណើរការគឺសំដៅទៅដល់ការអនុវត្តនូវប្រតិបត្តិការដែលបានកំណត់ទុកជាមុនតាមលំដាប់បន្តគ្នាលើទិន្នន័យបញ្ចូល ដើម្បីបញ្ចេញជាទិន្នន័យឬព័ត៌មាន[6]។

**២.២.២ ដំណើរការនៃការប្រមូលពន្ធ**

ក្នុងក្របខ័ណ្ឌ នៃការអនុវត្តន៍កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ព្រមជាមួយនឹងផែនការយុទ្ធសាស្ត្រ ២០១៨-២០២៣ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅ និង មុតស្រួចរបស់រដ្ឋាភិបាលនីតិកាល ទី៥ នៃរដ្ឋសភា អគ្គនាយកដ្ឋានពន្ធដារបានផ្តោតជាចម្បងលើការកែទម្រង់រដ្ឋបាលសារពើពន្ធ តាមរយៈការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងពង្រឹងអភិបាលកិច្ចល្អ ដោយបានពង្រឹង និងកែលើមុខងារស្នូល និងមុខងារគាំទ្រ ព្រមទាំងការកែទម្រង់គោលនយោបាយសារពើពន្ធ សំដៅបង្កើតប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ក្នុងការប្រមូលពន្ធ និងបំពេញភារកិច្ច និងបេសកកម្មប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌។ ជាលទ្ធផល ក្នុងរយៈពេល៦ឆ្នាំជាប់ៗគ្នាចុងក្រោយនេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធអាករសម្រេចបានលើផែនការដែលកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ រហូតដល់មាន ឆ្នាំខ្លះ ទទួលបានសន្ទស្សន៍កំណើន ២ខ្ទង់។ ជាក់ស្តែងនៅឆ្នាំ២០១៥ ការប្រមូលពន្ធអាករសម្រេចបានលើសផែនការប្រចាំឆ្នាំ ១១,៨% និងបន្តលើសផែនការជាបន្តបន្ទាប់ ដែលនៅក្នុងឆ្នាំ២០១៧ និង២០១៨ សម្រេចបានលើសផែនការប្រមាណ ១៥% ហើយក្នុងឆ្នាំ២០១៩ មានការកើនឡើងបន្ថែមទៀតរហូតដល់ ២៣,២% [7]។

ប្រសិនបើទីប្រឹក្សារបស់អ្នកជាប់ពន្ធមិនបានយកចិត្តទុកដាក់រៀបចំការប្រកាសឱ្យបានត្រឹមត្រូវ អ្នកជាប់ពន្ធអាចបង់ពន្ធមិនត្រឹមត្រូវតាមច្បាប់។ រដ្ឋបាលសារពើពន្ធនឹងតម្រូវឱ្យអ្នកជាប់ពន្ធអាចមានជម្រើសក្នុងការបង់ប្រាក់ជៀសវាងការបង់ប្រាក់យឺត និង ភាពធ្វេសប្រហែសរបស់អ្នកជាប់ពន្ធមិនគោរព តាមច្បាប់របស់អគ្គនាយកដ្ឋានពន្ធដា[8]។

[6] សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២១ បោះពុម្ពថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០២៤ ក្នុងបណ្ណាល័យ*សាកលវិទ្យាល័យវ៉ាន់ដា* ទំព័រទី១៧

[7] សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២១ បោះពុម្ពថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០២៤ ក្នុងបណ្ណាល័យ*សាកលវិទ្យាល័យវ៉ាន់ដា* ទំព័រទី២៤

[8] សាកលវិទ្យាល័យវ៉ាន់ដា (២០២៣). ដំណើរការនៃការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ: បោះពុម្ពថ្ងៃទី១ ទំព័រទី១៤

### ២.២.៣ ទ្រឹស្តីប្រមូលពន្ធ

ក្រោយពីបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងក្រសួងផ្សេងទៀតដែលពាក់ព័ន្ធ គ្រប់អ្នកជាប់ពន្ធ ត្រូវជាប់កាតព្វកិច្ចចុះបញ្ជីជាមួយនឹងរដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥ថ្ងៃ នៃការសកម្មភាពអាជីវកម្មរបស់ខ្លួន។ មុនឆ្នាំ២០១៦ អ្នកជាប់ពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ គឺអ្នកជាប់ពន្ធរបបម៉ៅការ និង អ្នកជាប់ពន្ធរបបពិត (ជាធម្មតាសំដៅដល់អ្នក ជាប់ពន្ធ របបស្វ័យប្រកាស)។ អ្នកជាប់ពន្ធរបបម៉ៅការ សំដៅដល់អ្នកជាប់ពន្ធតូចដែលខុស ពី អ្នកជាប់ពន្ធរបបស្វ័យប្រកាសដែលពន្ធត្រូវបានកំណត់ជាផ្លូវការសម្រាប់រយៈពេលមួយជាក់លាក់ក្នុងកំឡុងឆ្នាំនោះ។ អ្នកជាប់ពន្ធរបបស្វ័យប្រកាស សំដៅលើអ្នកដែលមានផលរបរប្រចាំឆ្នាំលើសពី៥០០លានរៀល។ (១២៥០០០ដុល្លារ) ពីការផ្គត់ផ្គង់ទំនិញ ឬ២៥០ លានរៀល (៦២៥០០ ដុល្លារ) ពីការផ្គត់ផ្គង់សេវាកម្ម និង១២៥លានរៀល (៣១២៥០ដុល្លារ) ក្នុងករណីផលរបរជាប់ពន្ធបានមកពីកិច្ចសន្យារដ្ឋាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៦ ដែលបានអនុម័តនាពេលថ្មីៗនេះ (ព្រះរាជក្រមលេខនស/រក/១២១៥/០១៦) មានការកែប្រែច្រើនលើច្បាប់ស្តីពីសារពើពន្ធ។ របបពន្ធម៉ៅការ ត្រូវបានលុបចោល ហើយសហគ្រាសទាំងឡាយណាដែលមានផលរបរប្រចាំឆ្នាំជាមធ្យម តិចជាង២៥០ លានរៀល មិនតម្រូវឱ្យបង់ពន្ធទេ។ អាជីវកម្មណាដែលមានផលរបរប្រចាំឆ្នាំលើសពី ២៥០លានរៀល នឹងត្រូវបង់ពន្ធលើតម្លៃបន្ថែម ត្រូវប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំប្រមូល និងបង់ពន្ធកាត់ទុកជាក់ស្តែង និងត្រូវធ្វើសវនកម្មពន្ធដារ។ ទន្ទឹមនឹងនេះ ច្បាប់ថ្មីក៏មានការកែប្រែនូវពន្ធរបបពិតដោយចែកជាបីប្រភេទ គឺអ្នកជាប់ពន្ធតូច មធ្យម និងធំ [9]។

## ២.៣ ផលប្រយោជន៍នៃការប្រមូលពន្ធដល់សង្គមជាតិ

### ២.៣.១ និយមន័យ

ការបង់ពន្ធ គឺជាការចូលរួមចំណែកក្នុងថវិកាជាតិ ដើម្បីឱ្យរដ្ឋមានលុយយកទៅចំណាយ ដោយមិន ចាំបាច់បោះពុម្ពលុយ ដែលអាចបង្កឱ្យមានបញ្ហាអតិផរណា។ សម្រាប់កម្ពុជា ការបង្កើនចំណូលពីការបង់ពន្ធ គឺជាគន្លឹះដ៏សំខាន់មួយ ដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេស។

ប្រយោជន៍នៃការបង់ពន្ធ គឺសម្រាប់អ្នកបង់ពន្ធ ថ្វីដ្បិតតែពន្ធនេះមិនមានការកំណត់អំពីសេវាណាមួយជាថ្នូរមកវិញជាក់លាក់ក៏ពិតមែន ក៏ប៉ុន្តែគេអាចទទួលបានផលប្រយោជន៍ជាច្រើនដោយផ្ទាល់ ឬដោយប្រយោលពីការបង់ពន្ធនេះ ពីព្រោះថា លុយដែលបានពីការបង់ពន្ធនេះនឹងត្រូវយកទៅចំណាយទៅលើការបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលជាអ្នកទទួលបន្ទុកផ្តល់សេវារដ្ឋបាល ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសជាតិ [10]។

### ២.៣.២ ប្រវត្តិនៃការបង់ពន្ធប៉ាតង់

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ពុំមានប្រភព ឬកំណត់ត្រាឯកសារជាប្រវត្តិសាស្ត្រជាក់លាក់ច្បាស់ការណាមួយដែលនៅសេសសល់ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ដើម្បីយកមកធ្វើជាមូលដ្ឋានសម្រាប់ចងក្លេង និងរំលេចសាវតារ និងប្រវត្តិនៃពន្ធដារកម្ពុជានៅក្នុងសៀវភៅនេះ

[9] សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២១ (បោះពុម្ពថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤) ក្នុងបណ្ណាល័យ*សាកលវិទ្យាល័យវ៉ាន់ដា* ទំព័រទី១៣

[10] *សាកលវិទ្យាល័យវ៉ាន់ដា*. (2024). *ច្បាប់ពន្ធដារកម្ពុជា* បោះពុម្ពលើកទី១

ថា តើពន្ធដារកម្ពុជាមានកំណើតពីកម្រិតណា និងមានរចនាសម្ព័ន្ធជាក់លាក់ពិតប្រាកដបែបណានោះទេ[11]។ និយាយរួម បច្ចុប្បន្ននេះ គឺពុំមានព័ត៌មានច្បាស់ការណាមួយស្តីពីសាវតារ ឬប្រវត្តិពន្ធដារកម្ពុជា ក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥ នោះទេ ប៉ុន្តែបើយោងតាមការនិយាយតៗគ្នារបស់បុគ្គលមួយចំនួនដែលធ្លាប់មានការពាក់ព័ន្ធជាមួយពន្ធដារកម្ពុជានៅក្នុងសម័យកាលទសវត្ស១៩៦០ និង ១៩៧០ គឺមុនរបបប្រល័យពូជសាសន៍ ប៉ុល ពត បានបញ្ជាក់ថា ពន្ធដារកម្ពុជាបានចាប់ផ្តើមមានកំណើតតាំងពីសម័យអាណានិគមបារាំង គឺមុនកម្ពុជាទទួលបាននូវឯករាជ្យពីអាណានិគមបារាំងក្នុងឆ្នាំ១៩៥៣។ សូមបញ្ជាក់ថា ឯកសារ ឬកំណត់ត្រាប្រវត្តិសាស្ត្រមួយចំនួនរបស់កម្ពុជា ត្រូវបានកម្ទេចចោល ឬបាត់បង់ក្នុងរបប ប៉ុល ពត។ បន្ទាប់ពីថ្ងៃរំដោះជាតិមាតុភូមិ ៧ មករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃប្រវត្តិសាស្ត្រដ៏ថ្លៃថ្លានៃការរស់រានមានជីវិតឡើងវិញពីរបបប្រល័យពូជសាសន៍ និង ជាសម័យកាលដ៏ខ្មៅងងឹតពោរពេញទៅដោយ សោកនាដកម្ម ដែលស្ថានភាព និងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជាទាំងមូលត្រូវលិចលង់ ធ្លាក់ចុះដុនដាបក្រោមកម្រិតសូន្យទៅទៀត ដោយសារការកម្ទេច និងរំលាយចោលដោយរបប កម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ហើយដែលប្រជាជនកម្ពុជា និងពិភពលោកទាំងមូលមិនអាចបំភ្លេចបាន។ កម្ពុជានៅពេលនោះបានចាប់ផ្តើមសាជាថ្មីនូវការខិតខំប្រឹងប្រែងកសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិឡើងវិញពីចំណុចក្រោមសូន្យលើគ្រប់វិស័យទាំងអស់ដោយរាប់ចាប់ពីវិស័យអប់រំ សុខាភិបាល និងសេដ្ឋកិច្ចទាំងមូល។ កត្តាអាទិភាពចម្បងទីមួយ របស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជានៅពេលនោះ គឺការខិតខំបង្កើត និងរក្សាសុខសន្តិភាពជូនប្រទេសជាតិ គឺការខិតខំគ្រប់បែបយ៉ាងក្នុងការការពារកុំឱ្យមានការវិលត្រឡប់មកវិញ នូវរបបប្រល័យពូជសាសន៍ប៉ុលពត ក្នុងពេលដែលកម្ពុជាកំពុងខិតខំកសាង និងស្តារប្រទេសជាតិឡើងវិញ។ នាថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានដាក់ចេញនូវសេចក្តីប្រកាសមួយស្តីពីការបង្កើតរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏បានបង្កើតឡើងវិញនូវប្រព័ន្ធគ្រប់គ្រងរដ្ឋ ការផ្តល់សេវាសាធារណៈ និងការស្តារតំបន់ឧស្សាហកម្មសំខាន់ៗសម្រាប់ជំរុញសកម្មភាពសេដ្ឋកិច្ច។ នៅដើមឆ្នាំ ១៩៨០ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានដាក់ឱ្យដំណើរការនូវការប្រមូលចំណូលថវិការដ្ឋនៅតាមផ្ទះលក់ទំនិញ និងកន្លែងធ្វើអាជីវកម្មធំៗមួយចំនួនតែប៉ុណ្ណោះ ក្រោមរូបភាពជាការធ្វើវិភាគទានដែលជាដែនសមត្ថកិច្ចរបស់អង្គភាពមន្ទីរហិរញ្ញវត្ថុ ដើម្បីជំរុញវិស័យសេដ្ឋកិច្ចឱ្យកាន់តែមានសកម្មភាពជួសជុលបន្ថែមទៀត។ នៅឆ្នាំ១៩៨១ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានចេញសេចក្តីសម្រេចអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុវត្តជាគំរូនូវកិច្ចប្រតិបត្តិការចុះឈ្មោះអាជីវកម្ម ប្រមូលពន្ធអាជីវកម្ម និងពន្ធលើទំនិញនាំចូលចំពោះមូលដ្ឋានមួយចំនួន តាមរយៈលិខិតលេខ ៧៨ ស.រ.ច ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៨១។ ផ្អែកតាមខ្លឹមសារនៃសារាចរលេខ ២៤៩-៨១ កហវ.ពដ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៨១ ។

ការអនុវត្តជាគំរូនេះ គឺអនុវត្តតែនៅក្នុងរាជធានីភ្នំពេញ ទីរួមខេត្តកណ្តាល និងស្រុកពញាឮតែប៉ុណ្ណោះ ហើយប្រមូលពន្ធតែទៅលើមូលដ្ឋានអាជីវកម្មផ្នែកពាណិជ្ជកម្ម ហូបចុក និងបម្រើការងារ ដែលកិច្ចការនេះស្ថិតក្រោមដែនសមត្ថកិច្ចរបស់នាយកដ្ឋានពន្ធដារឧស្សាហពាណិជ្ជកម្ម។ ក្នុងពេលជាបណ្តោះអាសន្នការប្រមូលពន្ធទាំងនេះ គឺអនុវត្តបានតែចំពោះមូលដ្ឋានមួយចំនួនដែលមានលក្ខណៈនឹងនរ ព្រមទាំងមាន

[11] Transparency International Cambodia. (2010). *ករណីសិក្សាអំពីប្រព័ន្ធពន្ធដារ.* Retrieved May, 12 2025, from https://ticambodia.org/library/wp (Page37).

កម្រិតផលរបរមធ្យមប្រចាំខែ តាមតារាងដែលបានកំណត់ ពោលគឺមិនទាន់ធ្វើការប្រមូលពន្ធអាជីវកម្មដល់មូលដ្ឋានទាំងឡាយណាដែលលក់ដូរអចល័ត ហើយមានផលរបរមធ្យមប្រចាំខែស្ថិតក្រោមកម្រិតដែលតម្រូវឱ្យបង់ពន្ធ និងបណ្តាមូលដ្ឋានអាជីវកម្មចល័តដែលយកផលិតផល កសិកម្ម ឬសត្វចិញ្ចឹមដោយផ្ទាល់មកលក់នៅទីផ្សារ។ ចំពោះផ្នែកផលិតកម្ម សិប្បកម្មតូចតាច ផ្នែកសំណង់ ដឹកជញ្ជូន នេសាទ និងផ្នែកផ្សេងៗទៀតត្រូវបានដាក់ឱ្យបន្តសិក្សាស្រាវជ្រាវដើម្បីរៀបចំ ដាក់អនុវត្តការប្រមូលពន្ធនៅពេលក្រោយ។

នៅចុងឆ្នាំ១៩៨២ ជាជំហានបន្ទាប់ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានដាក់អនុវត្តឱ្យប្រមូលពន្ធកាន់តែទូលំទូលាយក្នុងក្របខ័ណ្ឌទូទាំងប្រទេសលើកលែងតែខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី តាមរយៈក្រឹត្យច្បាប់លេខ ១៤ ក្រ.ច ចុះថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ១៩៨២ ។ បន្ទាប់មក ក្រសួងហិរញ្ញវត្ថុ បានដាក់អនុវត្តប្រកាសលេខ ២១៤៩-៨២ កហវ ចុះថ្ងៃ ទី ២០ ខែធ្នូ ឆ្នាំ ១៩៨២ ស្តីពីការណែនាំអនុវត្តក្រឹត្យ-ច្បាប់ពន្ធអាជីវកម្មចំពោះមុខ ដែលតម្រូវឱ្យប្រមូលពន្ធចំពោះ មូលដ្ឋានអាជីវកម្មចល័ត និង អចល័តដែលនៅក្នុងផ្នែកពាណិជ្ជកម្មហូបចុក និងបម្រើការងារ ដែលកំពុងមានសកម្មភាពក្រោមរូបភាពឯកជន ឬសមូហភាព ដូចជា ក្រុមហ៊ុន សមាគម ក្រុម សាមគ្គី សហករណ៍ ក្រុមហ៊ុនចម្រុះរដ្ឋជាដើម។ ចំពោះរបៀបរបបនៃការកំណត់ពន្ធសម្រាប់ការប្រមូលពន្ធនេះ គឺមិនគិតតាមអត្រាទេ ប៉ុន្តែត្រូវគិតតាមផលរបរប្រចាំខែ និងកំណត់ប្រាក់ពន្ធត្រូវបង់តែម្តង មានន័យថា បើផលរបរប្រចាំខែតិច គឺបង់ពន្ធតិច បើផលរបរច្រើន គឺបង់ពន្ធច្រើន[12]។

### ២.៣.៣ ទ្រឹស្តី

ពន្ធប៉ាតង់ ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ ពន្ធប៉ាតង់ ត្រូវបង់នៅរដ្ឋបាលសារពើពន្ធ ដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ។បណ្ណពន្ធប៉ាតង់មានតម្លៃចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងបណ្ណពន្ធប៉ាតង់តែប៉ុណ្ណោះ។ ករណីមានការ ផ្លាស់ប្តូរទីកន្លែងទៅរាជធានី-ខេត្តផ្សេងគ្នា ឬផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី ត្រូវបង់ប្រាក់ពន្ធប៉ាតង់ថ្មីម្តងទៀត។ ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នង់ថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវា អ្នកជាប់ពន្ធត្រូវមានបណ្ណពន្ធប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវាទាំងនោះ។ អ្នកជាប់ពន្ធ ត្រូវមានកាតព្វកិច្ចដាក់តាំងបង្ហាញពន្ធប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។ ក្នុងករណីអ្នកជាប់ពន្ធមិនបានដាក់តាំងបង្ហាញបណ្ណពន្ធប៉ាតង់ ត្រូវបានចាត់ទុកថា ប្រព្រឹត្តអំពើនាំឱ្យរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ស្របតាមមាត្រា ១២៨ និងមាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ[13]។

[12] Transparency International Cambodia(2010). *ករណីសិក្សាអំពីប្រព័ន្ធពន្ធដារ.* Retrieved May, 12 2025, from https://ticambodia.org/library/wp

[13] *អគ្គនាយកដ្ឋានពន្ធដារ.* (បោះពុម្ពឆ្នាំ ២០១០ )https://www.tax.gov.kh

# ជំពូកទី៣
# ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ



រដ្ឋខ្មែរបានចាប់កំណើតតាំងពីសតវត្សទី១នៃគ្រិស្តសករាជមកម្ល៉េះ ពោលគឺសម័យកាលហ្វូណន។ តាមប្រវត្តិសាស្ត្របន្តពីហ្វូណន មានសម័យកាល ជាច្រើនទៀតរួមមានចេនឡា អង្គរលង្វែក ឧដុង្គ និងចតុមុខ ដែលមានរយៈពេលប្រមាណជា១,៥០០ឆ្នាំ។ នៅក្នុងសម័យកាលទាំងនេះ យើងសង្កេតឃើញថា ព្រះរាជាបានប្រមូលពន្ធពីប្រជារាស្ត្រ ដោយសារព្រះអង្គបានប្រទានដីធ្លីដល់ប្រជារាស្ត្រ ដើម្បីប្រកបអាជីវកម្ម ឬកសិកម្មជាដើម។ អគ្គនាយកដ្ឋានពន្ធដារពីដំបូងឡើយមានឈ្មោះថា នាយកដ្ឋានពន្ធដារ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៣។ ចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ប្រព័ន្ធពន្ធដារត្រូវលុបបំបាត់ចោលទាំងស្រុងដោយរបបប្រល័យពូជសាសន៍ប៉ុលពត។ក្នុងឆ្នាំ១៩៨០ ដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ។ នៅក្នុងឆ្នាំ២០០៨ នាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារ ដែលស្ថិតនៅក្រោមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-១៩៥៣:នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើង

-១៩៧៥-១៩៧៩:ប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់(របបប្រល័យពូជសាសន៍ ឬរបបប៉ុលពត)

-១៩៨០-១៩៩៣:នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជក្រសួងហិរញ្ញវត្ថុ

-១៩៩៣-២០០៨: នាយកដ្ឋានពន្ធដារ(អង្គភាពពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

-២០០៨: ឡើងទៅជានាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ

#### ក.ចក្ខុវិស័យ

ចក្ខុវិស័យខាងលើ បានក្លាយជាអង្គការសាធារណៈដែលគួរឱ្យទុកចិត្ត និងគោរពទទួលស្គាល់ដោយគុណភាព និងជំនាញរបស់យើងក្នុងការប្រមូលចំណូលពន្ធ ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចនិងនិរន្តរភាពនៃប្រទេសកម្ពុជា។

ចក្ខុវិស័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ផ្សារភ្ជាប់ទៅនឹងចក្ខុវិស័យនៃការអភិវឌ្ឍកម្ពុជាដោយផ្ដោតទៅលើ ការប្រមូលចំណូលនៅក្នុងស្រុកឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។ កម្ពុជាមានចក្ខុវិស័យសម្រេចឱ្យបាននូវឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដោយចំណូលសម្រាប់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំនឹងកើនឡើងដល់រង្វង់ ៤.០០០ ទៅ ៥.០០០ ដុល្លារអាមេរិកនៅឆ្នាំ២០៣០ តាមរយៈការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចរបស់ជាតិ ដែលមានមូលដ្ឋានរឹងមាំ និងភាពធន់ខ្ពស់សមធម៌នៃការបែងចែកផ្លែផ្កានៃកំណើនការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាបាននូវប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ដែលមានបរិយាបន្នផ្តល់ឱកាសស្មើគ្នា និងប្រកបដោយយុត្តិធម៌។ ក្នុងន័យនេះ ចំណូលក្នុងស្រុករបស់កម្ពុជានឹងក្លាយជាឃ្នាស់យ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ការផ្តល់ការងារជូនប្រជាពលរដ្ឋ តាមរយៈការបែងចែកឡើងវិញនូវផលទុនជាតិក្នុងក្របខ័ណ្ឌនៃប្រព័ន្ធថវិកាជាតិដ៏សមស្របមួយ។ ម៉្យាងវិញទៀត ការកៀរគរចំណូលឱ្យអស់សក្តានុពល គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ពង្រឹងភាពជាម្ចាស់លើការអភិវឌ្ឍន៍ប្រទេសជាតិ និងបំពេញឱ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវចំណាយសាធារណៈចាំបាច់នានា ដើម្បីចូលរួមវិភាគទានដល់ការសម្រេចឱ្យបាននូវការអភិវឌ្ឍន៍ប្រទេសជាតិ។

### ខ.បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មផ្តល់នូវសេវាកម្មដែលមានគុណភាព ពង្រឹងការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព សាមញ្ញភាព និងសមធម៌ ចំណូលពន្ធដារ ប្រកបដោយចីរភាព ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ដើម្បីជំរុញ អ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្ត ឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធដារប្រកបដោយចីរភាពក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមានការផ្តល់ ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធ ប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ។
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្មការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌទៅតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារ។
- ប្រមូលចំណូលពន្ធទៅតាម ការអនុវត្តន៍ឱ្យត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ។
- ផ្តល់សេវា និងការអប់រំដល់អ្នកជាប់ពន្ធដើម្បីធានាបាននូវច្បាប់នានាស្តីពីពន្ធដារដែលត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ។
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនឱ្យបាននូវការជឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ។
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ។
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព។ បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈ គោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

### គ.គោលដៅ

ដើម្បីសម្រេចគោលនូវបំណងដែលបានរៀបរាប់ខាងលើរួមទាំងយុទ្ធសាស្ត្រកៀរគរចំណូលរបស់អគ្គនាយកដ្ឋានពន្ធដាររយៈពេលមធ្យមមានគោលដៅដូចតទៅ ៖

- ប្រមូលចំណូលចរន្តសរុបធ្វើឱ្យកើនឡើងបានយ៉ាងតិចបំផុត ០,៥ពិន្ទុភាគរយបន្ថែមលើផលធៀបរវាងចំណូលចរន្ត នឹងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំដោយត្រូវកើនពី ១៥,១៨% នៅក្នុងឆ្នាំ ២០១៤ ដល់ ១៧,៣៥% នៅឆ្នាំ២០១៨។
- ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចគោលដៅអភិវឌ្ឍជាតិដែលស្របនឹង យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ។
- ពង្រីកនូវលំហថវិកា ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រប់គ្រងបំណុលប្រកបដោយចីរភាព និងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស។
- បង្កើនធនធានថវិកា សម្រាប់តម្រូវការបន្ទាន់ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល នាពេលអនាគត។

### ឃ.គុណតម្លៃ

ការអនុវត្ត ៖យើងអនុវត្តនីតិរដ្ឋ គាំទ្រអ្នកដែលចង់ធ្វើអ្វីដែលត្រឹមត្រូវ និងរឹងមាំជាមួយអ្នកដែលមិនបានអនុលោមតាមច្បាប់។

វិជ្ជាជីវៈ៖យើងធ្វើសកម្មភាពដោយការលះបង់ និងជំនាញ ដើម្បីផ្តល់នូវដំណើរការដ៏សាមញ្ញ មានភាពងាយស្រួល។

ប្រសិទ្ធភាព ៖ យើងប្រើប្រាស់ធនធានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

សុចរិតភាព ៖ យើងប្រព្រឹត្តចំពោះមនុស្សដោយយុត្តិធម៌។

ការគោរព៖ យើងចាត់ទុកមនុស្សដោយសេចក្តីថ្លៃថ្នូរ និងការគោរព។

ភាពបត់បែន៖ យើងឆ្លើយតបយ៉ាងសកម្មចំពោះបញ្ហាប្រឈម និងទាញយកអត្ថប្រយោជន៍ពីឱកាស។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

#### ក. រចនាសម្ព័ន្ធគ្រប់គ្រង



យោងតាមមាត្រា៣៨ អគ្គនាយកដ្ឋានពន្ធដារមានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានដូចខាងក្រោម៖

- ថ្នាក់កណ្តាល
  - នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
  - នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
  - នាយកដ្ឋាននីតិកម្មគោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
  - នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
  - នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
  - នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
  - នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
  - នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម
  - នាយកដ្ឋានសវនកម្មសហគ្រាស
  - សាលាជាតិពន្ធដារ ថ្នាក់ស្មើនាយកដ្ឋាន
  - ទីចាត់ការពន្ធដាររាជធានីភ្នំពេញ ថ្នាក់ស្មើនាយកដ្ឋាន។

សាលាជាតិពន្ធដារ និងទីចាត់ការពន្ធដាររាជធានីភ្នំពេញ ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ជាជំនួយការ។

- ថ្នាក់មូលដ្ឋាន

នៅខណ្ឌនានានៃរាជធានីភ្នំពេញ និងខេត្តនីមួយៗ មានសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដោយប្រធានមួយរូបមានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួនមានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ។ នៅស្រុក ក្រុងមានការិយាល័យពន្ធដារស្រុក ក្រុង មានឋានៈស្មើការិយាល័យនៃសាខាពន្ធដារខេត្ត-ខណ្ឌ និងដឹកនាំដោយប្រធានមួយរូបអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

សាខាពន្ធដារមានខណ្ឌចំនួន៩ ស្ថិតនៅតាមខណ្ឌនៃរាជធានីនៅភ្នំពេញ និងនៅតាមបណ្តាខេត្តចំនួន ២៤ខេត្ត

- សាខាពន្ធដារខណ្ឌ

១. សាខាពន្ធដារខណ្ឌ ឫស្សីកែវ
២. សាខាពន្ធដារខណ្ឌ ដូនពេញ
៣. សាខាពន្ធដារខណ្ឌ ៧មករា
៤. សាខាពន្ធដារខណ្ឌ មានជ័យ
៥. សាខាពន្ធដារខណ្ឌ ចំការមន
៦. សាខាពន្ធដារខណ្ឌ ទួលគោក
៧. សាខាពន្ធដារខណ្ឌ ដង្កោ

៨. សាខាពន្ធដារខណ្ឌ សែនសុខ

៩. សាខាពន្ធដារខណ្ឌ ពោធិ៍សែនជ័យ

❖ សាខាពន្ធដារខេត្ត

១. សាខាពន្ធដារខេត្ត កណ្ដាល

២. សាខាពន្ធដារខេត្តកំពង់ចាម

៣. សាខាពន្ធដារខេត្ត បាត់ដំបង

៤. សាខាពន្ធដារខេត្ត ព្រៃវែង

៥. សាខាពន្ធដារខេត្ត សៀមរាប

៦. សាខាពន្ធដារខេត្ត កំពង់ធំ

៧. សាខាពន្ធដារខេត្ត តាកែវ

៨. សាខាពន្ធដារខេត្ត ស្វាយរៀង

៩. សាខាពន្ធដារខេត្ត ពោធិ៍សាត់

១០. សាខាពន្ធដារខេត្ត កំពង់ឆ្នាំង

១១. សាខាពន្ធដារខេត្ត កំពង់ស្ពឺ

១២. សាខាពន្ធដារខេត្ត កំពត

១៣. សាខាពន្ធដារខេត្ត ព្រះសីហនុ

១៤. សាខាពន្ធដារខេត្ត កោះកុង

១៥. សាខាពន្ធដារខេត្ត ព្រះវិហារ

១៦. សាខាពន្ធដារខេត្ត ក្រចេះ

១៧. សាខាពន្ធដារខេត្ត រតនគិរី

១៨. សាខាពន្ធដារខេត្ត មណ្ឌលគិរី

១៩. សាខាពន្ធដារខេត្ត បន្ទាយមានជ័យ

២០. សាខាពន្ធដារខេត្ត ស្ទឹងត្រែង

២១. សាខាពន្ធដារខេត្ត កែប

២២. សាខាពន្ធដារខេត្ត ប៉ៃលិន

២៣. សាខាពន្ធដារខេត្ត ឧត្ដរមានជ័យ

២៤. សាខាពន្ធដារខេត្ត ត្បូងឃ្មុំ។

**ខ. តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារមានតួនាទី និងភារកិច្ចដូចតទៅៈ

- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋានស្ដីពីពន្ធដារ កំណត់បញ្ជីឯកសារ និងលិខិតយុត្តិការនានា សម្រាប់ការគ្រប់គ្រងប្រមូលពន្ធ។
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិចុះបញ្ជីអ្នកជាប់ពន្ធ។

- ផ្ដល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ ផ្ដល់សេវា និងព័ត៌មានដល់អ្នកជាប់ពន្ធដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ។
- កសាងកម្មវិធីសវនកម្មលើអ្នកជាប់ពន្ធ។
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ចំពោះអ្នកជាប់ពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ។
- ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។
- អនុវត្តវិធានការតឹងរឹង និងដាក់ទោសទណ្ឌតាមច្បាប់ ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ។
- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ។
- រៀបចំ និងអនុវត្តកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ។
- ចូលរួមរៀបចំគម្រោងថវិកាជាតិ និងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

### ៣.១.៤ និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ

## ៣.២ ដំណើរការក្នុងការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ មូលហេតុនៃការប្រមូលពន្ធប៉ាតង់

រដ្ឋាភិបាល មិនមែន ចេះតែមានផែនការដំឡើងអត្រាពន្ធ និងបង្កើតច្បាប់ពន្ធថ្មីៗនោះទេ ប៉ុន្តែ រដ្ឋាភិបាលនឹងពង្រីកវិសាលភាពក្នុងប្រមូលពន្ធក្នុងប្រទេស ពីព្រោះ មានអ្នកជាប់ពន្ធភាគច្រើនមិនទាន់ដឹង ពីសារៈសំខាន់នៃការបង់ពន្ធ។ នេះបើយោងតាមមន្ត្រីជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ **លោក គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ** បានថ្លែងក្នុងវេទិកាស្ដីពីពន្ធដារ ថាគោលនយោបាយរដ្ឋាភិបាលនឹងធ្វើកំណែទម្រង់ពន្ធដារ និងពង្រីកឱ្យអស់សមត្ថភាពក្នុងការប្រមូលពន្ធ ពីព្រោះ ក្រុមហ៊ុនជាច្រើនមិនទាន់មកចុះបញ្ជីនៅក្នុងអគ្គនាយកដ្ឋានពន្ធដារនៅឡើយ។ មូលហេតុចម្បងតែមួយគត់ដែលត្រូវបង់ពន្ធនោះគឺ ដើម្បីចិញ្ចឹមរដ្ឋរបស់អ្នកឱ្យដំណើរការទៅមុខ។ អ្នកជាប់ពន្ធត្រូវបង់ពន្ធ ពីព្រោះ ប្រាក់របស់អ្នកនឹង ជួយឱ្យរាជរដ្ឋាភិបាលអាចចំណាយទៅលើប្រាក់ខែមន្ត្រីរាជការ អាចប្រើប្រាស់នៅក្នុងវិស័យសាធារណៈដូចជា សាងសង់សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ របនាសម្ព័ន្ធតាមដងផ្លូវសាធារណៈ ទាំងនៅក្នុងទីក្រុង តាមបណ្ដាខេត្ត ភូមិ ឃុំ និង

វិស័យសន្តិសុខផងដែរ។ ក្នុងលក្ខខណ្ឌដែលអ្នកជាប់ពន្ធគេចវេស ឬមិនបានបំពេញកាតព្វកិច្ចនោះទេ អ្នកជាប់ពន្ធអាចប្រឈមមុខ ដោយត្រូវពិន័យជាសាច់ប្រាក់រហូតអាចឈានដល់ការផ្អាក ឬបញ្ឈប់អាជីវកម្ម ក៏ដូចជាប្រឈមមុខនឹងច្បាប់ផងដែរ ។

### ៣.២.២ ដំណើរការនៃការប្រមូលពន្ធ

កាលពីមុនអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ធ្វើការបង់ប្រាក់ពន្ធ និង ស្នើសុំទម្រង់លិខិតប្រកាសពន្ធ នៅតាមសាខាពន្ធដារនិងតាមសាខាខណ្ឌរៀងៗខ្លួន។ ប៉ុន្តែដោយមានភាពលំបាកពេកសម្រាប់មន្ត្រីពន្ធក៏ដូចជាអ្នកជាប់ពន្ធរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់មួយចំនួនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយធ្វើការផ្លាស់ប្ដូរនីតិវិធីក្នុងការប្រមូលពន្ធ-អាករ និងការដាក់លិខិតប្រកាសពន្ធផ្សេងៗឲមានលក្ខណៈទំនើបនិងងាយស្រួលសម្រាប់អ្នកជាប់ពន្ធនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

- **ការប្រមូលប្រាក់អាករ**

ការប្រមូលប្រាក់អាករ នាពេកបច្ចុប្បន្នក៏ដូចជាការប្រមូលប្រាក់ពន្ធដទៃទៀតដែរ គឺអ្នកជាប់ពន្ធទាំងទាំងអស់ត្រូវការគណនាពន្ធដោយខ្លួនឯង បំពេញលិខិតប្រកាសពន្ធ ហើយធ្វើការបង់នៅធនាគារដើម្បីផ្ដល់សុវត្ថិភាពដល់ថវិការរដ្ឋ។

- ជម្រើសទី១

ដើម្បីមានភាពងាយស្រួល និងឆាប់រហ័សទាន់ចិត្តអ្នកជាប់ពន្ធក៏អាចចូលទៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ដោយស្វែងរកពាក្យ"ការប្រកាសបង់ប្រាក់ពន្ធ» ហើយអនុវត្តន៍ តាម លំដាប់លំដោយ និងការណែនាំនៅក្នុងគេហទំព័រដូចខាងក្រោម៖

- បំពេញការិយបរិច្ឆេទនៃការបង់ពន្ធរបស់ខ្លួន (ខែ ឆ្នាំ ពីថ្ងៃ ដល់ថ្ងៃ) ឧទាហរណ៍៖ ចាប់ពីថ្ងៃទី១ខែមករា រហូតដល់ថ្ងៃទី៣១មីនា

- ជ្រើសរើសប្រភេទពន្ធ និងបំពេញចំនួនទឹកប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទពន្ធនីមួយៗដូចក្នុងលិខិតប្រកាស

- ជ្រើសរើសកម្រៃសេវាផ្សេងៗ និងបំពេញទឹកប្រាក់ដែលត្រូវបង់(ប្រសិនបើមាន)។

- ត្រូវបំពេញចំនួនទំព័រនៃទម្រង់លិខិតប្រកាសនីមួយៗ

- នៅពេលបំពេញរួចត្រូវបោះពុម្ព (Print)លិខិតស្នើសុំបង់ប្រាក់ពន្ធចេញពីប្រព័ន្ធគ្រប់គ្រងដែលមាន Barcode សម្រាប់សម្គាល់ចេញពីម៉ាស៊ីនបោះពុម្ព (Printer)ហើយអ្នកជាប់ពន្ធអាចយកលិខិតនេះទៅបង់ពន្ធនៅធនាគារណាមួយដែរទទួលប្រាក់បង់ពន្ធ។

❖ ជម្រើសទី២

ក្នុងករណីអ្នកជាប់ពន្ធមិនសូវចេះប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធ Online អ្នកជាប់ពន្ធត្រូវទៅធនាគារណា មួយទទួលបន្ទុកទទួលប្រាក់បង់ពន្ធ ហើយអនុវត្តន៍តាមជំហាននីមួយៗដូចខាងក្រោម៖

- បំពេញទម្រង់បង់ប្រាក់ពន្ធ (Form101) នូវប្រភេទពន្ធ និងចំនួនទឹកប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទ ពន្ធនីមួយៗដូចក្នុងលិខិតប្រកាស

- ដាក់ទម្រង់បង់ប្រាក់ពន្ធ (Form101) ដែលបំពេញរួចជូនរដ្ឋមន្ត្រីធនាគារដើម្បីបង់ប្រាក់ពន្ធ។ ធនាគារ ចំនួនបីដែលមានការទទួលខុសត្រូវក្នុងការប្រមូលពន្ធជូនដល់រដ្ឋមានដូចជា ៖
ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ក.អ និងធនាគារវឌ្ឍនៈ។

ក្នុងនោះដែរ ដើម្បីឲ្យម្ចាស់សហគ្រាសទាំងអស់យល់ដឹងពីដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយដ្ឋានពន្ធដារ ត្រូវផ្សព្វផ្សាយអំពីនីតិវិធីនៃការបង់ពន្ធប៉ាតង់ទៅកាន់ម្ចាស់សហគ្រាសទាំងអស់តាមរយៈទូរទស្សន៍ កាសែត ទស្សនាវដ្ដី វេបសាយរបស់ពន្ធដារការធ្វើសិក្ខាសាលាទាក់ទងនិងការប្រមូលពន្ធរបស់ឯកឧត្តម គង់ វិបុល ស្ដីអំពីដំណើរការនៃការប្រមូលពន្ធលើប្រាក់ បៀវត្ស និងលិខិតណែនាំផ្សេងៗ ឬការចុះទៅផ្ទាល់ដល់ទីតាំងរបស់អាជីវកម្មទាំងអស់និងពន្យល់ឲ្យដល់ម្ចាស់អាជីវកម្មយល់ពីច្បាប់និងបញ្ញត្តិផ្សេងៗពីការបង់ពន្ធដូចជា៖

- នីតិវិធីនៃការចុះឈ្មោះក្នុងបញ្ជីពន្ធដារ
- ការដាក់លិខិតប្រកាស និងពេលវេលាកំណត់នៃការបង់ពន្ធ
- ពន្យល់ដល់ម្ចាស់សហគ្រាសពីការកាត់ទុកនូវប្រាក់ពន្ធលើប្រាក់បៀវត្សពីនិយោជិត
- អត្ថប្រយោជន៍ពីការបង់ពន្ធលើប្រាក់បៀវត្ស
- នីតិវិធីនៃការប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ
- ការធ្វើសវនកម្មពន្ធដារ និងការកំណត់ឡើងវិញ
- សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ។

➢ **ការគេចវេសពន្ធ**

យើងដឹងហើយថាការបង់ពន្ធ គឺជាកាតព្វកិច្ចមួយដ៏ចាំបាច់ របស់អ្នកជាប់ពន្ធ។ យ៉ាងណាមិញអ្នកជាប់ពន្ធ ច្រើនតែចង់កាត់ បន្ថយពន្ធដែលពួកគេត្រូវបង់ជូនរដ្ឋហើយ ដោយតាមរយៈនីតិវិធី ឬ វិធីស្របច្បាប់ផ្សេងៗ ឬគេហៅថា ការជៀសពន្ធ។ តែបើមានការ ប្រព្រឹត្តនូវមធ្យោបាយខុសឆ្គង ដើម្បីកាត់បន្ថយប្រាក់ ពន្ធនោះវានឹង ក្លាយទៅជាការគេចវេះពន្ធ ហើយវាជាអំពើខុសច្បាប់ បើយោង ទៅ

តាមច្បាប់ស្តីពីសារពើពន្ធ។ការគេចវេះពន្ធ (មាត្រា ២២៦នៃច្បាប់ស្តីពីសារពើពន្ធ) គឺ ជាអំពើណាមួយ ដែលបានប្រព្រឹត្តឡើងដោយចេតនា និងរៀបចំ ទុកជាមុន ដែលនាំឱ្យបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។

ត្រូវបានចាត់ទុកថាជាការគេចវេសពន្ធផងដែរចំពោះករណីណាមួយដូចខាងក្រោម៖

> ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រព្រឹត្តឡើងបី លើកឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេល១០(ដប់)ឆ្នាំនៃឆ្នាំប្រតិទិន។

កាតព្វកិច្ចបង់ពន្ធ ជាកិច្ចការមួយដែលប្រជាពលរដ្ឋត្រូវតែធ្វើតាមសេចក្តីសម្រេចរបស់រដ្ឋ ដើម្បីជួយ សម្រួលដល់កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋ។ ដូច្នេះ កាតព្វកិច្ចបង់ពន្ធចាំបាច់ណាស់ ត្រូវតែធ្វើ ប្រសិនបើ ភ្លេចប្រហែលជាអាចនឹងមានបញ្ហាកាន់តែធ្ងន់ធ្ងរ សម្រាប់អ្នកនៅពេលអនាគតដោយសារតែពន្ធ នោះវាកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ ការមិនបង់ពន្ធ អាចប្រឈមមុខនឹងការពិន័យតាមផ្លូវច្បាប់ថែម ទៀត។ ចំពោះបុគ្គលដែលមានការធ្វេសប្រហែស ត្រូវរងនូវប្រាក់ពន្ធបន្ថែមដែលស្មើនឹង១០ភាគរយ នៃ ចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់២ភាគរយនៃចំនួនប្រាក់ពន្ធ ដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់។ ចំពោះបុគ្គល ដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ត្រូវរងប្រាក់ពន្ធបន្ថែមដែលស្មើនឹង ២៥ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះបូកបន្ថែមការប្រាក់២ ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

យោងតាមមាត្រា២២៥ នៃច្បាប់សារពើពន្ធស្តីពីអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវបានចាត់ទុកជាអំពើ ដែលប្រព្រឹត្តផ្ទុយពីការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេង ទៀតដូចជា៖

១. ការមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ស្របតាមការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋាន គតិយុត្តិពាក់ព័ន្ធផ្សេងទៀត។

២. ការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរព័ត៌មាននៃការចុះបញ្ជី។

៣. ការមិនបានដាក់លិខិតប្រកាសសារពើពន្ធ។

៤. ការមិនបានប្រើប្រាស់ប្រព័ន្ធកត់ត្រាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៥. ការមិនបានចេញវិក្កយបត្រ។

៦. ការមិនផ្តល់ព័ត៌មាន ឬមិនបញ្ជូនរបាយការណ៍តាមការស្នើសុំ។

៧. ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យឬឯកសារផ្សេងៗ។

៨. ការមិនបានរក្សាបញ្ជីកាគណនេយ្យនិងឯកសារផ្សេងទៀត។

៩. ការព្យាយាមរារាំងការកំណត់ និងការប្រមូលពន្ធ។

១០. ការកសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។

១១. ការលាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។

១២. ការចេញវិក្កយបត្រក្លែងបន្លំ។

១៣. ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។

**៣.២.៣.នីតិវិធីនិងក្រុមហ៊ុនដែលត្រូវចុះបញ្ជីពន្ធប៉ាតង់**

- ការចុះបញ្ជីពន្ធដារ

១- បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធ។ បុគ្គលដែលមានកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអាទិ៍មានៈ

**ក.** ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ។

**ខ.** ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សាខាក្រុមហ៊ុនបរទេស ការិយាល័យតំណាងសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហគ្រាសសាធារណៈ សហគ្រាសរដ្ឋ និងក្រុមហ៊ុនចម្រុះរដ្ឋ។

**គ.** សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**ឃ.** បុគ្គលដទៃទៀតដែលធ្វើសកម្មភាពអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- បុគ្គលដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ ត្រូវបានតម្រូវឱ្យចុះបញ្ជីពន្ធដារស្របតាមចំណាត់ចាត់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬកម្រិតផលរបរ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងត្រូវស្នើសុំចុះបញ្ជីទៅតាមទ្រង់ទ្រាយគតិយុត្តនៃបុគ្គលស្នើសុំដូចខាងក្រោមៈ

ក. បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ១ នៃប្រការនេះ ចំពោះការចុះបញ្ជីពន្ធដារត្រូវធ្វើឡើងតាមរយៈគេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservices.gov.kh ស្របទៅតាមការកំណត់ ដូចមានចែងក្នុងអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបុគ្គលដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃគេហទំព័រចុះបញ្ជីអាជីវកម្ម និងទទួលបានឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារជាទម្រង់ឌីជីថលដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជីអាជីវកម្មនេះ។

ខ. បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ក វាក្យខណ្ឌ គ និងវាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការនេះ ឬបុគ្គលណាមួយដែលមានបំណងចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬមិនអាចធ្វើការចុះបញ្ជីតាមគេហទំព័រចុះបញ្ជីអាជីវកម្មបាន។ ការចុះបញ្ជីពន្ធដារ ត្រូវធ្វើឡើងតាមរយៈការបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវ ដូចមានកំណត់ក្នុងពាក្យ ស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់១០១) ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

៣-រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងប្រាក់ពន្ធកម្រៃសេវាដោយបញ្ជាក់កាលបរិច្ឆេទ នៃការប្រគល់ ទទួលបន្ទាប់ពីបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំនោះត្រឹមត្រូវ និងគ្រប់គ្រាន់។ ដោយឡែក ការស្នើសុំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធរបស់

បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ១ ក្នុងប្រការនេះ រដ្ឋបាលសារពើពន្ធត្រូវបំប្លែងឯកសារបញ្ចូលព័ត៌មានការស្នើសុំចុះបញ្ជាក់ពីការទទួលពាក្យនៃការស្នើសុំចុះបញ្ជី និងប្រាក់ពន្ធកម្រៃសេវាចុះបញ្ជីបន្ទាប់ពីបានទទួលការបញ្ជាក់អគ្គនាយកដ្ឋានពន្ធដារ https://www.registrationservices.gov.kh ឱ្យបានរួចរាល់ និងត្រូវចេញលិខិតជាសារអេឡិចត្រូនិកបញ្ជាក់ការទទួលពាក្យស្នើសុំពីគេហទំព័រចុះបញ្ជីអាជីវកម្ម។

**៣.២.៤ បែបបទនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**

ពន្ធប៉ាតង់ត្រូវបានប្រមូលមួយដងក្នុងមួយឆ្នាំនៅដើមឆ្នាំ ចាប់ពីថ្ងៃទី០១ ខែ០១ រហូតដល់ថ្ងៃទី៣១ ខែ០៣ នៃឆ្នាំត្រូវបង់ពន្ធ។ សហគ្រាស ឬអាជីវកម្មដ្ឋានដែលបានចុះបញ្ជី ឬចាប់ផ្តើមប្រកបអាជីវកម្មក្នុង៦ខែដើមឆ្នាំ ត្រូវបង់ពន្ធប៉ាតង់ពេញមួយឆ្នាំ។ បើចាប់ផ្តើមចុះបញ្ជី ឬប្រកបអាជីវកម្ម៦ខែចុងឆ្នាំ ត្រូវជាប់ពន្ធកន្លះឆ្នាំ។ ករណីសហគ្រាសពាណិជ្ជកម្ម ឬសេវាកម្មដែលមានសាខាលក់ទំនិញ ឬបំរើការងារដែលត្រូវបង់ប៉ាតង់តាមថ្នាក់ដូចគ្នា ផលរបរដើម្បីកំណត់ប្រាក់ពន្ធ ត្រូវបូកផលរបរបញ្ចូលគ្នារបស់សាខា និងសហគ្រាសមេ ដើម្បីគិតពន្ធប៉ាតង់ត្រូវបង់នៅសហគ្រាស។ រដ្ឋបាលពន្ធដារត្រូវតែចេញប័ណ្ណប៉ាតង់បន្ទាប់បន្សំជូនទៅសាខាទាំងនោះ ហើយសហគ្រាសដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរតែមួយ ស្ថិតក្នុងភូមិសាស្ត្រខេត្តក្រុងតែមួយ មិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ។ ក្នុងករណីមានមុខរបរផ្សេងៗគ្នា ឬមានទីតាំងស្ថិតនៅខេត្តក្រុងផ្សេងៗគ្នា ត្រូវបង់ពន្ធប៉ាតង់តាមមុខរបរនីមួយៗ និងទៅតាមខេត្តក្រុងដែលសាខា ឃ្លាំង រោងចក្រ រោងជាងនោះតាំងនៅ។ សហគ្រាសដែលមានមុខរបរច្រើន ត្រូវជាប់ពន្ធប៉ាតង់ផ្សេងគ្នាតាមមុខរបរនីមួយៗ ដែលត្រូវបានកំណត់ដូចខាងក្រោម៖

- បើធ្វើការបែងចែកផលរបរទៅតាមផ្នែកមុខរបរដែលត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នា ទើបត្រូវប្រមូលផ្សេងគ្នាតាមមុខរបរ ហើយចំពោះមុខរបរនីមួយៗ ត្រូវចេញប័ណ្ណប៉ាតង់មួយ។ បើបែងចែកមិនបង់ពន្ធប៉ាតង់ ត្រូវប្រមូលលើផលរបរសរុបតាមថ្នាក់ពន្ធប៉ាតង់របស់មុខរបរ ដែលមានផលរបរខ្ពស់បំផុត។
- ជាគោលការណ៍សម្រាប់សហគ្រាសដែលបានបង់ពន្ធប៉ាតង់ក្នុងឆ្នាំរួចហើយ ត្រូវតែអនុវត្តទៅតាមលក្ខខណ្ឌដូចតទៅ៖ ប្រសិនបើ ក្នុងករណីផ្លាស់ប្តូរ ទីកន្លែង នៅខេត្តក្រុងផ្សេង ឬ ផ្លាស់ប្តូរ មុខរបរអាជីវកម្ម ចាត់ទុកថាទើបចាប់ផ្តើមអាជីវកម្ម ត្រូវបង់ពន្ធប៉ាតង់ថ្មី លើកលែងតែរដ្ឋបាលមូលដ្ឋានទទួលស្គាល់ថា ត្រូវមានគោលការណ៍ផ្លាស់ប្តូរជំរុញលើកទឹកចិត្ត តែត្រូវសុំប្តូរប័ណ្ណប៉ាតង់។
- ក្នុងករណីត្រូវប្តូរម្ចាស់ ម្ចាស់ថ្មីត្រូវបង់ពន្ធប៉ាតង់ថ្មី លើកលែងតែម្ចាស់ថ្មីនោះជាឪពុក ឬម្តាយ ប្តីប្រពន្ធស្របតាមច្បាប់ ជាអ្នកស្នងស្របច្បាប់របស់ម្ចាស់អាជីវកម្ម ប៉ុន្តែម្ចាស់ថ្មីត្រូវប្តូរប័ណ្ណប៉ាតង់ថ្មី។
- ពន្ធប៉ាតង់ ត្រូវបង់នៅកន្លែងសុំប្រកបអាជីវកម្ម ឬកន្លែងសុំចុះបញ្ជីសារពើពន្ធដែលជាកន្លែងមានទីស្នាក់ការសហគ្រាសតាំងនៅ។




- ការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិច

ការរីកចម្រើនក្នុងផ្នែកបច្ចេកវិទ្យា បានធ្វើការជម្រុញឱ្យមានការរីកលូតលាស់នូវអាជីវកម្មតាមរយៈប្រព័ន្ធអនឡាញជាច្រើនវិស័យ ដូចដែលលោកអ្នកបានសង្កេតឃើញនាពេលបច្ចុប្បន្ននេះ។ ប្រជាពលរដ្ឋជាច្រើនបានចាប់ផ្តើមការប្រកបរបរអាជីវកម្មរបស់ខ្លួនតាមប្រព័ន្ធអនឡាញ ដោយហេតុថា វាមានភាពងាយស្រួលចំពោះទំនាក់ទំនង ការផ្សព្វផ្សាយផលិតផល និងការទូទាត់ប្រាក់ ក៏ដូចជាការបំលាស់ទីក្នុងការធ្វើកិច្ចការងារផ្សេងៗទៀតជាដើម។ ជាមួយគ្នានេះ កាលពីថ្ងៃទី០២ ខែឧសភា

ឆ្នាំ២០២០កន្លងទៅ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវបានអនុម័ត ដើម្បីធ្វើការគ្រប់គ្រងទៅលើការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិច ឬអនឡាញ ក្នុងគោលបំណងសម្រួល និងជម្រុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។ ជាការពិតណាស់ គ្រប់ការប្រកបអាជីវកម្មទាំងអស់ គឺត្រូវមានការស្នើសុំច្បាប់អនុញ្ញាត ឬចុះបញ្ជីឱ្យបានត្រឹមត្រូវ។ ចំពោះការប្រកបអាជីវកម្មតាមអនឡាញក៏ដូចគ្នា ដោយយោងទៅលើប្បញ្ញត្តិច្បាប់ជាធរមាន ការប្រកបអាជីវកម្មតាមអនឡាញនេះ វាពាក់ព័ន្ធជាមួយនឹងស្ថាប័នសំខាន់ៗមិនខុសពីការប្រកបអាជីវកម្មខាងក្រៅទូទៅនោះទេ ដូចជាក្រសួង ឬមន្ទីរពាណិជ្ជកម្ម។ នៅពេលខាងមុខនេះ អង្គភាពពន្ធដារនឹងត្រូវអនុម័តច្បាប់បន្ថែមទៀត ដែលការប្រកបអាជីវកម្មបែបនេះ នឹងពាក់ព័ន្ធជាមួយនឹងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ផងដែរ។ អេឡិចត្រូនិចទាំងក្នុង និងក្រៅប្រទេសផ្តល់នូវទំនុកចិត្ត និងការការពារដល់អ្នកប្រើប្រាស់ជាដើម។

ដើម្បីត្រៀមខ្លួន និងបំពេញនូវលក្ខខណ្ឌផ្សេងៗក្នុងការធ្វើអាជីវកម្ម ឬពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិចរបស់លោកអ្នកឱ្យមានភាពត្រឹមត្រូវស្របទៅតាមនីតិវិធីច្បាប់ ក្នុងគ្រប់ការប្រកបអាជីវកម្មតាមអនឡាញ ដែលមានចំណូលផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀលឡើងទៅ។ នៅពេលលោកអ្នកធ្វើការប្រកបអាជីវកម្ម អនុវត្តស្របទៅតាមច្បាប់ វានឹងធ្វើឱ្យអាជីវកម្មរបស់លោកអ្នកកាន់តែទទួលបាននូវទំនុកចិត្ត ការទាក់ទាញនូវអតិថិជន និងការប្រកួតប្រជែងនៅលើទីផ្សារដោយស្មើភាព។ ក្នុងករណីដែលលោកអ្នកខកខានមិនបានបំពេញនូវកាតព្វកិច្ចចុះបញ្ជីនោះទេ ការប្រកបអាជីវកម្មរបស់លោកអ្នក គឺប្រព្រឹត្តទៅដោយខុសច្បាប់ ដែលអាចធ្វើឱ្យលោកអ្នកប្រឈមជាមួយនឹងការផាកពិន័យនៅពេលដែលការអនុវត្តន៍ច្បាប់ត្រូវបានរឹតបន្តឹងនាពេលខាងមុខ។ ដូច្នេះ លោកអ្នកគួរត្រៀមខ្លួនឱ្យបានរួចរាល់ សម្រាប់អាជីវកម្មរបស់លោកអ្នក ដើម្បីកាត់បន្ថយនូវហានិភ័យ និងផ្តល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការពង្រីកអាជីវកម្មឆ្ពោះទៅមុខ។ លោកអ្នកត្រូវរៀបចំបំពេញបែបបទក្នុងការចុះបញ្ជីអាជីវកម្មឱ្យបានឆាប់រហ័សបំផុត និងស្វែងយល់ពីកាតព្វកិច្ចនានាដែលពាក់ព័ន្ធ ជាពិសេស គឺកាតព្វកិច្ចសារពើពន្ធនៅអង្គភាពពន្ធដារ។

**+កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់ និងប័ណ្ណប៉ាតង់**

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះអ្នកប្រកបអាជីវកម្មតាមអនឡាញ ដែលមានចំណូលផលរបរប្រចាំឆ្នាំចាប់ពី ២៥០-១០០០លានរៀល អ្នកជាប់ពន្ធតូចត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល។

២- ចំពោះអ្នកជាប់ពន្ធមធ្យម ដែលមានចំណូលផលរបរប្រចាំឆ្នាំចាប់ពី ១០០០-៦០០០ លានរៀល អ្នកជាប់ពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល។

៣- ចំពោះអ្នកជាប់ពន្ធធំដែលមានចំណូលផលរបរប្រចាំឆ្នាំ អ្នកជាប់ពន្ធធំលើសពី ៦០០០ លានរៀល អ្នកជាប់ពន្ធធំត្រូវបង់៖

ក-ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៣ ០០០ ០០០ រៀល។

ខ-ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៥ ០០០ ០០០ រៀល ក្នុងករណីដែលមានផលរបរលើសពី ១០ ០០០ លានរៀល។




៤- អ្នកជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រានេះ ដែលចាប់ផ្តើមប្រកបរអាជីវកម្មក្នុងរយៈពេល៦ខែចុងឆ្នាំ ត្រូវបង់ប៉ាតង់ចំនួនពាក់កណ្តាលនៃប៉ាតង់ប្រចាំឆ្នាំ។

អ្នកជាប់ពន្ធដែលមានទីកន្លែងអាជីវកម្មជាគោលដើម ទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ អប្បបរមាសម្រាប់ប្រភេទអ្នកជាប់ពន្ធនីមួយៗនៅតាមរាជធានី-ខេត្ត និងកន្លែងផ្សេងទៀតដែលអាជីវកម្មនោះស្ថិតនៅ។

ប័ណ្ណពន្ធប៉ាតង់មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណពន្ធប៉ាតង់តែប៉ុណ្ណោះ ករណីមានការផ្លាស់ប្តូរទីកន្លែងទៅរាជធានី ខេត្តផ្សេង ផ្លាស់ប្តូរមុខរបរអាជីកម្មថ្មី ត្រូវបង់ប្រាក់ពន្ធប៉ាតង់ថ្មីម្តងទៀត។

ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬការស្ទាបស្ទង់តម្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកជាប់ពន្ធត្រូវមានប័ណ្ណពន្ធប៉ាតង់ ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពីព្រោះជាតម្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មទាំងនោះ។

អ្នកជាប់ពន្ធ ត្រូវមានកាតព្វកិច្ចដាក់តាំងបង្ហាញប័ណ្ណពន្ធប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។ ក្នុងករណីអ្នកជាប់ពន្ធមិនបានដាក់តាំងបង្ហាញប័ណ្ណពន្ធប៉ាតង់ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្ដីពីពន្ធដារ ស្របតាមមាត្រា១២៨ និងមាត្រា ១៣៣ នៃច្បាប់សារពើពន្ធ។


ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
លេខ/N°PTM23012601825 អពជ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ ២០២២
អ្នកជាប់ពន្ធមធ្យម

ឈ្មោះសហគ្រាស៖ ក្រុមហ៊ុនសាកល្បង7134
លេខអត្តសញ្ញាណកម្មសារពើពន្ធ៖ K007-9022XXXXX
ចុះបញ្ជីនៅ៖ អគ្គនាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រង៖ សាខាពន្ធដារខណ្ឌមានជ័យ
ទ្រង់ទ្រាយសហគ្រាស៖ សហគ្រាសឯកបុគ្គល
សកម្មភាពអាជីវកម្មចម្បង៖ សណ្ឋាគារនិងសណ្ឋាគាររីសត
អាសយដ្ឋានសហគ្រាស៖ #174 ផ្លូវ9040 ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
ឈ្មោះម្ចាស់សហគ្រាស៖ មន ចាន់រដ្ឋធីន សញ្ជាតិ៖ ខ្មែរ

PATENT TAX 2022
Medium Taxpayer

Company's name : Companytest1125
Tax Identification Number (TIN) : K007-9022XXXXX
Registered at : General Department of Taxation Under : Mean Chey Tax Branch
Main business activity(ies) : test
Forms of business : Sole proprietorship
Owner's name : MORN CHANROTHIN Nationality: Cambodian

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣
Phnom Penh,26 January 2023

អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation

ទឹកប្រាក់ពន្ធប៉ាតង់ ២០២២
១,២០០,០០០ រៀល
លេខ SN: 900081662
900081663

បញ្ជាក់ ៖ ប័ណ្ណប៉ាតង់នេះត្រូវដាក់តាំង ឬព្យួរ នៅទីកន្លែងប្រកបអាជីវកម្ម។
Note : This patent tax must be hanged or displayed at the company's office.

**៣.២.៥ ការឈប់ ផ្អាក និងផ្លាស់ប្ដូរម្ចាស់អាជីវកម្ម**

- ❖ យោងតាមប្រកាស ៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១- សហគ្រាសដែលស្នើសុំឈប់ ឬផ្អាកអាជីវកម្ម នៅក្នុងឆ្នាំជាប់ពន្ធណាមួយ៖

ក-តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពាក់កណ្ដាល ប្រសិនបើដាក់ពាក្យសុំឈប់ ឬក៏ផ្អាកអាជីវកម្មនៅក្នុងអំឡុង ៦ខែចុងឆ្នាំនៃឆ្នាំចរន្ត។

ខ-តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពេញមួយឆ្នាំ ប្រសិនបើដាក់ពាក្យសុំឈប់ ឬក៏ផ្អាកអាជីវកម្មនៅក្នុងអំឡុង ៦ខែចុងឆ្នាំនៃឆ្នាំចរន្ត។ ប្រាក់ពន្ធប៉ាតង់ដែលបានបង់រួចហើយ មិនត្រូវបានបង្វិលសងវិញទេ។

២- ចំពោះអាជីវកម្មដែលផ្លាស់ប្តូរម្ចាស់ បើម្ចាស់ចាស់បានបង់ពន្ធប៉ាតង់ហើយ ម្ចាស់ថ្មីមិនបាច់បង់ពន្ធប៉ាតង់ជាថ្មីទៀតទេ ប្រសិនបើមានគ្រប់លក្ខខណ្ឌពីរខាងក្រោមនេះ៖

ក-មិនផ្លាស់ប្តូរសកម្មភាពអាជីវកម្ម។

ខ-ម្ចាស់ថ្មីជាឪពុក ម្តាយ ប្តី ប្រពន្ធ កូន ឬអ្នកស្នងដោយស្របច្បាប់ពីម្ចាស់អាជីវកម្មចាស់។

## ៣.៣ ផលប្រយោជន៍ដែលទទួលបានពីការបង់ពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.៣.១ អត្ថប្រយោជន៍ដែលទទួលបានពីការបង់ពន្ធប៉ាតង់ចំពោះសង្គមជាតិ

ជាការពិតណាស់ សម្រាប់អ្នកបង់ពន្ធ ថ្វីត្បិតតែការបង់ពន្ធនេះ មិនមានការកំណត់អំពីសេវាណាមួយជាថ្នូរមកវិញជាក់លាក់ក៏ពិតមែន ប៉ុន្តែគេអាចទទួលបាននូវផលប្រយោជន៍ជាច្រើនពីការបង់ពន្ធ ដោយផ្ទាល់ ឬដោយប្រយោល ជាក់ស្តែងចំពោះខ្លួនឯង និងសង្គមជាតិដូចជា៖

- បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ មន្ត្រីកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និវត្តន៍ជន និងការសាងសង់ធុរកិច្ច។
- ពន្ធប៉ាតង់អាចជួយឱ្យមានការអភិវឌ្ឍន៍ផ្សេងៗក្នុងសេដ្ឋកិច្ចពាក់ព័ន្ធនិង ឧស្សាហកម្ម កសិកម្ម ដោយប្រើប្រាស់សេវាកម្មប៉ាតង់ក្នុងការចំណាយ ឬផលិតផល។
- ការប្រមូលពន្ធប៉ាតង់អាចជួយសម្រួលការប្រើប្រាស់ធនធានធម្មជាតិ ឬស្រទាប់ធនធានក្នុងប្រទេស ដោយទាមទារដើម្បីប្រើប្រាស់ធនធានក្នុងវិស័យដែលមានការសន្និដ្ឋានជាសាធារណៈ។
- ពន្ធប៉ាតង់ អាចធ្វើឱ្យមានការរក្សាការប្រកួតប្រជែងសេដ្ឋកិច្ចក្នុងប្រទេស និងការពារអាជីវកម្មក្នុងប្រទេសមិនឱ្យមានការប្រកួតចេញពីពាណិជ្ជកម្មក្រៅប្រទេស។
- ប្រាក់ពន្ធនេះក៏បានជួយសម្រួលដល់ការចំណាយផ្សេងៗរបស់រដ្ឋ ហើយរដ្ឋក៏បានផ្តល់ប្រាក់ពន្ធនេះទៅដល់ថវិកាជាតិ និងថ្នាក់ក្រោមជាតិជាច្រើនដែរ។
- ពន្ធប៉ាតង់ដែលប្រមូលបានគឺ សម្រាប់ចំណាយទៅលើ
    - សេវាសាធារណៈមួយចំនួន៖
        - គ្រឿងឧបករណ៍នៅតាមក្រសួង
        - គ្រឿងសង្ហារឹម
        - សម្ភារៈការិយាល័យ
        - មន្ទីរ
        - ស្ថាប័ន
        - អង្គភាពចំណុះរដ្ឋ។
    - ហេដ្ឋារចនាសម្ព័ន្ធសង្គម៖
        - ផ្លូវថ្នល់
        - ស្ពាន

- សាលារៀន
- សាលាឃុំ
- មន្ទីរពេទ្យជាដើម។

○ វិស័យអប់រំ និងសុខាភិបាលៈ
  - ការសាងសង់មណ្ឌលសុខភាព
  - កសាងមន្ទីរពេទ្យរដ្ឋ។

○ ប្រាក់ពន្ធប៉ាតង់ក៏បានចំណាយលើៈ
  - វិស័យសន្តិសុខសណ្តាប់ធ្នាប់សង្គម
  - វិស័យការពារជាតិផងដែរ

- ការបង់ពន្ធ គឺជាការទទួលខុសត្រូវសង្គម និងបង្ហាញពីកាយវិការស្រេបច្បាប់របស់រដ្ឋផងដែរ។ ក្នុងការប្រមូលពន្ធប៉ាតង់។
- អគ្គនាយកដ្ឋានពន្ធដារក៏បានរកប្រាក់ចំណូលដ៏សំខាន់ជូនរដ្ឋផងដែរ។
- បង្កើនប្រាក់ចំណូលរបស់រដ្ឋប្រាក់ពន្ធប៉ាតង់ជាផ្នែកមួយនៃប្រាក់ចំណូលថ្នាលរដ្ឋដែលអាចប្រើសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។
- ប្រាក់ចំណូលនេះអាចយកទៅលើកកម្ពស់វិស័យសុខាភិបាល, អប់រំ, និងសេវាសាធារណៈផ្សេងៗ។
- លើកកម្ពស់អាជីវកម្មឲ្យស្ថិតក្នុងប្រព័ន្ធផ្លូវការ
- វាជួយឲ្យរដ្ឋអាចតាមដានបានពីសកម្មភាពសេដ្ឋកិច្ចនានានិងជួយលើកកម្ពស់អាជីវកម្មឲ្យមានស្ថេរភាព និងច្បាស់លាស់។
- លើកស្ទួយការងារ និងជម្រុញសេដ្ឋកិច្ចមូលដ្ឋាន
- ពន្ធប៉ាតង់ជួយអនុញ្ញាតឲ្យអាជីវកម្មតូចៗអាចប្រតិបត្តិបានយ៉ាងស្រួលក្រោមសិទ្ធិផ្លូវការ។
- ជួយអោយប្រជាពលរដ្ឋមានឱកាសបង្កើតការងារជាឯករាជ្យ ហើយជួយជម្រុញសេដ្ឋកិច្ចមូលដ្ឋានឲ្យរីកចម្រើន។
- ជួយក្នុងការរៀបចំការគ្រប់គ្រងរដ្ឋបាល និងគយសារពើពន្ធ
- ដោយមានទិន្នន័យពីអាជីវកម្មតូចៗ អាជ្ញាធរមានសមត្ថភាពក្នុងការរៀបចំយុទ្ធនាការប្រមូលពន្ធ និងគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ចឲ្យមានប្រសិទ្ធភាព។
- ជួយសង្កេតស្ថានភាពសេដ្ឋកិច្ចនៃប្រទេស
- ពន្ធប៉ាតង់ផ្តល់ទិន្នន័យសំខាន់សម្រាប់ការវិភាគ និងទស្សនៈអនាគតនៃសេដ្ឋកិច្ច, ជួយដល់ការរៀបចំគោលនយោបាយរដ្ឋ។
- ជួយបង្កើនការទទួលខុសត្រូវនិងធ្វើអោយមានវិន័យសេដ្ឋកិច្ច
- ការបង់ពន្ធប៉ាតង់ជួយដល់ការលើកទឹកចិត្តឲ្យប្រជាជនមានវិន័យក្នុងអាជីវកម្ម និង សហការជាមួយរដ្ឋ។

សរុបៈ ការប្រមូលពន្ធប៉ាតង់មិនត្រឹមតែជាការបង្កើនប្រាក់ចំណូលរដ្ឋទេ ប៉ុន្តែវាជាឧបករណ៍សំខាន់ក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចជាតិទាំងមូល។

### ៣.៣.២ ហានិភ័យនៃការមិនបង់ពន្ធប៉ាតង់

ជាទូទៅ ពន្ធប៉ាតង់ត្រូវបង់ចាប់ថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ តែបើមិនបានបង់ពន្ធប៉ាតង់ទៅតាមពេលវេលាកំណត់នោះទេ ម្ចាស់អាជីវកម្មត្រូវពិន័យពន្ធបន្ថែម១០% និងការប្រាក់១.៥% នៃការប្រាក់ប្រចាំខែ ដែលមិនបានបង់។ ក្នុងករណីមានការធ្វេសប្រហែសធ្ងន់ធ្ងរ ដោយធ្វើការជូនដំណឹងហើយ តែមិនបង់ពន្ធនោះ មិនមែនពិន័យ១០% ទៀតនោះទេ គឺ២៥% និងការប្រាក់១.៥%។ ម្យ៉ាងវិញទៀត បើម្ចាស់អាជីវកម្មមិនបានដាក់លិខិតប្រកាសពន្ធនោះទេ គឺត្រូវពិន័យពន្ធបន្ថែម៤០% និងបូកការប្រាក់១.៥% នៃពន្ធត្រូវបង់។ ក្នុងករណីម្ចាស់អាជីវកម្មមិនបានបង់ពន្ធតាមពេលវេលា ឬគេចវេសមិនព្រមបង់ពន្ធតាមច្បាប់ដែលនាយកដ្ឋានពន្ធដារបានកំណត់ នោះម្ចាស់អាជីវកម្មទាំងអស់នឹងជួបហានិភ័យដូចជា៖

- ផ្តល់ផលប៉ះពាល់ដល់អាជីវកម្មដែលទាក់ទងនិងច្បាប់
- ម្ចាស់អាជីវកម្មអាចនឹងប្រឈមមុខនឹងការផាកពិន័យ
- ធ្វើឱ្យអាជីវកម្ម ឬសហគ្រាសដែលកំពុងដំណើរការអាចប្រឈមមុខនឹងការបិទ
- ធ្វើឱ្យបុគ្គលិក កម្មករខ្វះការងារថ្មីធ្វើ ពិបាករកការងារធ្វើក្នុងករណីអាជីវកម្ម និងសហគ្រាសទាំងនោះត្រូវបានបិទទ្វារ
- ធ្វើឱ្យអាជីវកម្ម ឬសហគ្រាស ផ្អាកដំណើរការមួយរយៈក្នុងករណីធ្ងន់ធ្ងរ (ដូចជាការទទួលបានសំបុត្រក្រើនរំឮកពីនាយកដ្ឋានពន្ធដារជាច្រើនលើកច្រើនសារ ហើយនៅតែមិនទាន់បង់ពន្ធ ឬមិនព្រមទទួលយកនៅការផាកពិន័យ មិនតែប៉ុណ្ណោះ មិនព្រមចូលខ្លួនដោះស្រាយតាមកាលកំណត់ជាដើម)។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និង ចំណុចខ្សោយ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើនខែកន្លងមកនេះ ក្រុមយើងខ្ញុំបានប្រមូលផ្តុំនូវទិន្នន័យ និងព័ត៌មានសំខាន់ៗជាច្រើន ដើម្បីទុកធ្វើជាទុនក្នុងការវិភាគ ស្ទាបស្ទង់ វាស់វែង វាយតម្លៃ សិក្សាស្វែងយល់ពីដំណើរការនៃ ការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ ឱ្យបានកាន់តែស៊ីជម្រៅជាងមុនបន្ថែមទៀត។ អំឡុងពេលនៃការសិក្សាស្រាវជ្រាវនេះដែរ ក្រុមយើងខ្ញុំបានសង្កេតឃើញនូវចំណុចខ្លាំង និង ចំណុចខ្សោយរបស់អគ្គនាយកដ្ឋានពន្ធដារទៅលើដំណើរការនៃការប្រមូលពន្ធប៉ាតង់ដែលមានដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- អគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី សម្រាប់កត់ត្រាអត្តសញ្ញាណ របស់បុគ្គលណាដែលប្រព្រឹត្តខុសច្បាប់។
- កាត់បន្ថយការគេចវេសពីការបង់ពន្ធពង្រឹងនិងបង្កើនការគ្រប់គ្រងឱ្យបានកាន់តែប្រសើរឡើងនូវទិន្នន័យរបស់អ្នកជាប់ពន្ធ
- មានផ្តល់នូវសេវាសមស្របដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មានអប់រំ ចំណេះដឹង ការពន្យល់ណែនាំដែលទាក់ទងនិងការបង់ពន្ធឲអ្នកជាប់ពន្ធកាន់តែយល់ច្បាស់និងពេញចិត្តដោយស្មោះត្រង់
- ធ្វើឱ្យការប្រមូលពន្ធមានការកើនឡើង ក្នុងការជួយធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍន៍
- អគ្គនាយកដ្ឋានពន្ធដារផ្តល់នូវសេវាដែលមានគុណភាព តម្លាភាព និងការគោរពប្រកបដោយវិជ្ជាជីវៈ និងពង្រឹងនូវការអនុវត្តន៍ច្បាប់ ចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីឈានទៅរកការសម្រេចបាននូវការអភិវឌ្ឍន៍ និងលើកកម្ពស់សុខមាលភាពរបស់ប្រជាជនកម្ពុជា។
- អគ្គនាយកដ្ឋានពន្ធដារមានកំណត់ពេលវេលាយ៉ាងច្បាស់លាស់ នៅក្នុងការបង់ពន្ធសម្រាប់អ្នកជាប់ពន្ធទាំងអស់ ឱ្យអនុវត្តតាមយ៉ាងតឹងរឹង ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានបង់ពន្ធតាមកាលកំណត់នឹងត្រូវពិន័យជាសាច់ប្រាក់ ឬឈានដល់ការផ្អាក ឬបិទអាជីវកម្មផងក៏មាន។
- អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលចូលពន្ធដារ
- អាចសម្រួលដល់ចំណូលហិរញ្ញវត្ថុរបស់ជាតិ សម្រាប់ចំណាយដូចជា៖ សន្តិសុខ សុខមាលភាពសង្គម ការជួយឧបត្ថម្ភធនជានផ្សេងៗ និងសេវាសារជារណៈ
- ដើម្បីជំរុញឱ្យមានការលូតលាស់នូវសេដ្ឋកិច្ច និងឧស្សាហ៍កម្មក្នុងស្រុក
- មានបទបង្ហាញច្បាស់លាស់ និងមានសិក្ខាសាលាក្នុងការបង្ហាញច្បាប់ថ្មី ស្តីពីសវនកម្មពន្ធដារ ដែលមានភាពងាយស្រួលដល់អ្នកជាប់ពន្ធថ្មី និងចាស់អាចយល់ដឹងបន្ថែម។
- បានផ្តល់ជូននូវសេវាសមស្របដល់អ្នកជាប់ពន្ធ រួមមាន៖ ការផ្តល់ព័ត៌មានអប់រំចំណេះដឹង ការពន្យល់ណែនាំទាក់ទងនឹងការបង់ពន្ធផ្សេងៗ ដែលធ្វើឱ្យអ្នកជាប់ពន្ធយល់កាន់តែច្បាស់ និងពេញចិត្តបង់ពន្ធដោយភាពស្មោះត្រង់។

- មានផ្តល់នូវសេវាសមស្របដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មានអប់រំ ចំណេះដឹងការ ពន្យល់ ណែនាំ ដែលទាក់ទងនឹងពន្ធផ្សេងៗឱ្យអ្នកជាប់ពន្ធកាន់តែយល់ច្បាស់ និងពេញចិត្តដោយស្មោះត្រង់

## ៤.២ ការវិភាគលើចំណុចខ្សោយ

ជាធម្មតាអង្គភាពនីមួយៗ តែងតែមានចំណុចមិនល្អរៀងៗខ្លួន យ៉ាងណាមិញ ជាក់ស្តែងយើងឃើញថា អគ្គនាយកដ្ឋានពន្ធដារកម្ពុជាក៏នៅមានចំណុចខ្វះខាតបន្តិចបន្តួចផងដែរ។ ទោះបីពន្ធដារខិតខំរឹតបន្តឹងទប់ស្កាត់ទៅលើការគេចវេសយ៉ាងណាក៏ដោយនៅមាន ចំណុចធ្វេសប្រហែសមួយចំនួនដូចជាៈ

- ការផ្សព្វផ្សាយអំពីពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារពុំទាន់មានភាពជ្រួលជ្រាបដល់សាធារណៈជននៅឡើយទេ
- មានបំពេញកាតព្វកិច្ចបង់ពន្ធពីអ្នកជាប់ពន្ធនៅមានកម្រិត បណ្តាលមកពីអ្នកជាប់ពន្ធទទួលព័ត៌មានមិនបានគ្រប់ជ្រុងជ្រោយ
- មានការគេចវេសពន្ធពីសំណាក់អ្នកជាប់ពន្ធ មិនព្រមចុះបញ្ជីពន្ធប៉ាតង់ ទុកពេលលក់ឬផ្ទេរកម្មសិទ្ធិ ចាំបង់ពន្ធសរុប
- ការអនុវត្តលើការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់មិនសូវមានភាពសកម្មនិងមានយឺតយ៉ាវ
- កង្វះផែនការយុទ្ធសាស្ត្រពីការផ្តល់សេវា និងការអប់រំរបស់អ្នកជាប់ពន្ធនៅមានកម្រិតថ្នាក់កណ្តាល និងសាខាខេត្ត-ខណ្ឌ។
- មូលដ្ឋានទិន្នន័យអ្នកជាប់ពន្ធមិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាពពេញលេង
- កង្វះមន្ត្រីពន្ធដារៈ នៅមានការខ្វះខាតមួយចំនួនក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ ឬទៅដល់ម្ចាស់អាជីវកម្មដែលត្រូវមកបង់ពន្ធ និងការបំពេញលិខិតស្នាមផ្សេងៗនៅមានការរង់ចាំយូរក្នុងការទទួលសេវាកម្ម។
- នៅមានក្រុមហ៊ុន សហគ្រាស និងអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិចមួយចំនួនមិនទាន់មកចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារនៅឡើយ។
- ក្រុមហ៊ុនមួយចំនួនបានចុះបញ្ជីពន្ធដារមិនត្រឹមត្រូវ បណ្តាលឱ្យអំពើពុករលួយបង្អាក់ដំណើរការអាជីវកម្ម និងមិនបានអនុវត្តតាមបទប្បញ្ញត្តិពន្ធដារ ពីព្រោះភាគច្រើន ពួកគេបារម្ភអំពីការបង់សំណូកជូនមន្ត្រីពន្ធដារ។
- មន្ត្រីពន្ធមួយចំនួន គ្មានភាពទទួលខុសត្រូវក្នុងការងាររបស់ខ្លួន (ខ្លួនធ្វើខុស តែបង្វែរទៅដាក់អ្នកជាប់ពន្ធជាអ្នកធ្វើខុស អ្នកជាប់ពន្ធក្លាយជាជនរងគ្រោះ) ដូចជាការដាក់ឯកសារផ្សេងៗ គាត់បានឃើញចំណុចខុស ប៉ុន្តែមិនបានប្រាប់មកខាងអ្នកជាប់ពន្ធ ដើម្បីយល់បន្ថែម ឬកែតម្រូវភ្លាមៗឡើយ។
- អត្រាក្រុមហ៊ុនដែលមិនបានប្រកាសពន្ធ និងអនុវត្តច្បាប់ពន្ធនៅតែមានច្រើន (មានក្រុមហ៊ុនជាច្រើន ឧទាហរណ៍ៈ ក្រុមហ៊ុនចិនមួយចំនួនដែលបានបើកអាជីវកម្ម ក្រុមហ៊ុនពួកគាត់តែងតែគេចមិនអនុវត្តតាមច្បាប់)
- ករណីមន្ត្រីពន្ធ និងអ្នកជាប់ពន្ធឃុបឃិតគ្នាប្រព្រឹត្តអំពើពុករលួយនៅតែមាន (ឧទាហរណ៍ៈ អ្នកជាប់ពន្ធទៅដាក់លិខិតប្រកាសពន្ធនៅតាមបណ្តាសាខាណាមួយដែលគាត់ស្គាល់ ដោយគាត់បានស្គាល់មន្ត្រី

នៅទីនោះ ដូច្នេះពួកគេ គឺតែងតែមានសំណូក ដើម្បីទទួលបានសេវា ឬធ្វើឯកសារផ្សេងៗមុនអ្នកដទៃ ដែលមក មុនខ្លួន។)

- ទោះបីជាមានប្រព័ន្ធប្រមូលពន្ធតាមរបបស្វ័យប្រកាសក៏ដោយ តែអ្នកប្រើប្រាស់នៅតែរអ៊ូរទាំអំពីភាព យឺតយ៉ាវ និងការមានបញ្ហាបច្ចេកទេសនៃការប្រមូលពន្ធ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងវិភាគទៅលើប្រធានបទ "ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ" រួចមក ក្រុមរបស់ខ្ញុំអាចយល់បានថា ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកពន្ធដារមានដំណើរការបែបបទ ទម្រង់ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់ តួនាទីភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារជំនាញ និងទំនួលខុសត្រូវ ព្រមទាំងបានអនុវត្តនូវវិធានការនៃច្បាប់បានច្បាស់លាស់ពិតប្រាកដមែន។ វាក៏ជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារ ប្រមូលចំណូលចរន្តសរុបកើនឡើង និងឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ ដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ។

ម្យ៉ាងវិញទៀត ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារមានដំណើរការផ្តល់នូវសេវាកម្មដែលមានគុណភាព ពង្រឹងការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិប្រកបដោយតម្លាភាព រួមទាំងប្រសិទ្ធិភាពដើម្បីជម្រុញអ្នកជាប់ពន្ធឱ្យបំពេញនូវកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្ត។ ជាមួយគ្នានេះដែរ បែបបទនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបូកផលរបបញ្ចូលគ្នារបស់សាខា និងសហគ្រាសមេ ដើម្បីគិតពន្ធប៉ាតង់ដែលត្រូវបង់របស់សហគ្រាសបានយ៉ាងត្រឹមត្រូវច្បាស់លាស់។ យ៉ាងណាមិញ យើងបានឃើញថា អគ្គនាយកដ្ឋានពន្ធដារផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព ថ្លៃថ្នូរ និងការប្តេជ្ញាចិត្ត ដោយបានចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ ភាពរីកចម្រើន និងមានការអភិវឌ្ឍន៍នៅក្នុងប្រទេស។

សរុបមក យោងតាមការសិក្សាស្រាវជ្រាវ និងពិភាក្សាគ្នាយ៉ាងសកម្មនៃការធ្វើសារណារបស់ក្រុមនាងខ្ញុំទៅលើប្រធានបទ "**ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**" រួចមក ក្រុមរបស់នាងខ្ញុំអាចសន្និដ្ឋានបានថា ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ គឺពិតជាបានអនុវត្តយ៉ាងត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់ពន្ធចូលថវិកាជាតិគ្រប់គ្រាន់ ពិតប្រាកដមែន។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់រួចមកនូវការធ្វើសេចក្តីសន្និដ្ឋានស្តីពី ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ រួចមក ក្រុមរបស់នាងខ្ញុំក៏បានយល់ឃើញថា អគ្គនាយកដ្ឋានពន្ធដារបានគោរពទៅតាម គោលការណ៍របស់ខ្លួនបានយ៉ាងល្អិតល្អន់ ហ្មត់ចត់ ច្បាស់លាស់ និងត្រឹមត្រូវទៅតាមស្តង់ដារដែលបានកំណត់ និងអនុវត្តបានយ៉ាងល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងការប្រមូលពន្ធប៉ាតង់ ហើយក៏បានជួយជំរុញដល់ការអភិវឌ្ឍប្រទេសកម្ពុជាថែមមួយកម្រិតទៀត។ យើងទាំងអស់គ្នាបានដឹងស្រាប់ហើយថា រាល់ការចំណាយមួយចំនួននៅក្នុងប្រទេស គឺសុធសឹងតែយកថវិការដែលបានមកពីការប្រមូលពន្ធ ដើម្បីទៅផ្គត់ផ្គង់បើពុំមានប្រាក់ពន្ធនេះ រាជរដ្ឋាភិបាលក៏ពិបាកក្នុងការផ្គត់ផ្គង់ខ្ទង់ចំណាយទាំងនេះដែរ ពោលគឺមិនអាចទប់ទល់នឹង ការចំណាយទាំងអស់នេះបានឡើយ។ នៅខាងក្រោយនៃភាពជោគជ័យ និងភាពច្បាស់លាស់ទៅតាមស្តង់ដារនៃពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ យើងក៏បានសង្កេតឃើញថា ដំណើរការនៃការប្រមូលពន្ធនេះនៅមានចំណុចខ្វះខាត និងត្រូវកែលំអរនៅឡើយ នេះបើយោងទៅតាមការយល់ឃើញរបស់ក្រុមនាងខ្ញុំ។

ហេតុដូច្នេះហើយ ក្រុមនាងខ្ញុំសូមបញ្ចេញមតិយោបល់មួយចំនួនដល់ ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ ដែលស្ថិតក្នុងន័យស្ថាបនា ដើម្បីជួយជម្រុញឱ្យការងារនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋាន កាន់តែមានប្រសិទ្ធភាព សុក្រឹត្យ និងបានកាន់តែល្អជាងមុនថែមមួយកម្រិត ហើយហេតុផលទាំងនេះហើយដែលជំរុញឱ្យការងារ កាន់តែមានសក្ដានុពល។ ចំពោះចំណុចទាំងអស់នោះ មានដូចខាងក្រោម៖

- មន្ត្រីពន្ធដារត្រូវតែពង្រឹងការផ្សព្វផ្សាយអំពីពន្ធដារឲបានទូលំទូលាយដើម្បីឲអ្នកដែលមានកាតព្វកិច្ចបង់ពន្ធបានយល់ដឹងកាន់តែច្បាស់អំពីពន្ធ
- មន្ត្រីពន្ធដារត្រូវតែមានវិធានការក្នុងការរឹតបន្តឹងការគេចវេសមិនព្រមបង់ពន្ធឲខ្លាំងជាងនេះ
- មន្ត្រីពន្ធដារត្រូវតែមានទំនួលទុកត្រូវ ឲបានច្បាស់លាស់ក្នុងការបំពេញកាតព្វកិច្ចការងារ
- មន្ត្រីពន្ធដារត្រូវតែគោរពពេលវេលា ដោយដឹងថា ការងារណា សំខាន់ ការងារណាមិនសូវសំខាន់ ការងារណាបន្ទាន់ ការងារណាមិនសូវបន្ទាន់ ដើម្បីទប់ស្កាត់នូវភាពយឺតយ៉ាវក្នុងការដាក់បញ្ជូនឯកសារ ឬរបាយការណ៍ជូនទៅកាន់ថ្នាក់លើ ឬអង្គភាពដែលពាក់ព័ន្ធនានា។
- អគ្គនាយកដ្ឋានពន្ធដារត្រូវតែពង្រឹងទៅលើការត្រួតពិនិត្យរាល់ក្រុមហ៊ុន សហគ្រាស និងជាពិសេសអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិច ឱ្យបានកាន់តែហ្មត់ចត់ ដើម្បីជៀសវាងទៅលើការគេចវេសក្នុងការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ។
- ពន្ធដារត្រូវតែពង្រឹង និងទទួលស្គាល់នូវរាល់ចំណុចខ្វះខាត ឬមតិរិះគន់នានារបស់អ្នកជាប់ពន្ធ ក៏ដូចជាសាធារណៈជនដែលបានរាយការណ៍ ឬក៏តាមរយៈមធ្យោបាយផ្សេងៗ។
- មិនត្រូវចាត់ទុកចំណុចខ្វះខាតបន្តិចបន្តួចថា ជារឿងធម្មតា ហើយព្រងើយកន្តើយមិនព្រមផ្លាស់ប្តូរនោះឡើយ បើទោះបីកំហុសនោះប្រព្រឹត្តដោយចេតនា ឬអចេតនាក្តី។

# ឯកសារយោង


- Channel Youtube. General Department of taxation, Cambodia. (2024). រៀនអំពីពន្ធដារតាមអនឡាញ ស្តីពីពន្ធប៉ាតង់. Retrieved May, 26 2025, from https://www.youtube.com/watch?v=hSX006-a09k
- General Department of taxation, Cambodia. (2016). កម្រងលិខិតបទដ្ឋានគតិយុត្ត. *ពន្ធដារកម្ពុជា ២០១៦*
- សាលាជាពន្ធដារ. ២០១៦. ឯកសារវគ្គបណ្តុះបណ្តាលស្តីពី *សវនកម្មពន្ធដាររបស់សាលាជាតិពន្ធដារ*
- តាមរយៈគេហទំព័រ Facebook: ***Cambodian Tax Agent***
- វិទ្យាស្ថាន វ៉ាន់ដា. ឆ្នាំ២០២៣. *របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់២១* បោះពុម្ពលើកទី១ ៣៥ទំព័រ
- វិទ្យាស្ថាន វ៉ាន់ដា. (ឆ្នាំ២០២៤). *ច្បាប់ពន្ធដារកម្ពុជា.* បោះពុម្ពលើកទី១. ភ្នំពេញ
- Facebook. Kakcent. (2021). *ពន្ធ*. Retrieved May ,23 2025, from https://www.kakcent.com/business-tax/
- Taxation.gov.kh. ការចុះបញ្ជី. Retrieved May, 27 2025, from https://registrationservices.gov.kh/media/2022/08/Prakas-on-Tax-Registration-

# ឧបសម្ព័ន្ធ


រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
សៀវភៅណែនាំ
ស្ដីពី
ពន្ធប៉ាតង់
ឆ្នាំ ២០១៣
រៀបចំ និង បោះពុម្ពផ្សាយដោយ
អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រក្សាសិទ្ធិគ្រប់បែបយ៉ាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..១៥៧............សហវ.ប្រក

# ប្រកាស
## ស្តីពី
## វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញក្រឹត្យ-ច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធប៉ាតង់
- បានឃើញព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.. គោលបំណង**

ប្រកាសនេះ មានគោលបំណងកំណត់វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់លើសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីគ្រប់គ្រងនិងប្រមូលចំណូលពន្ធឱ្យមានប្រសិទ្ធភាពស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.. វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.. កម្មវត្ថុនៃពន្ធ**

ពន្ធប៉ាតង់ គឺជាពន្ធប្រចាំឆ្នាំដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធ និងកម្រិតផលរបរ។

**ប្រការ ៤.. បែបបទនៃការបង់ពន្ធ**

បែបបទនៃការបង់ពន្ធប៉ាតង់ ត្រូវបានកំណត់ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។

ឧទាហរណ៍÷ អ្នកជាប់ពន្ធម្នាក់ដែលមានសកម្មភាពអាជីវកម្មនីហរ័ណ-អាហរ័ណ ដឹកជញ្ជូន និងសណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់សម្រាប់ ៣ សកម្មភាពអាជីវកម្មផ្សេងគ្នា។

២- សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

ឧទាហរណ៍ទី១÷ សណ្ឋាគារមួយដែលមានក្លឹបកម្សាន្ត ភោជនីយដ្ឋាន កន្លែងម៉ាស្សា ក្លឹបហាត់ប្រាណ ឬសកម្មភាពដទៃដែលជាឧបសម្ព័ន្ធនៃសកម្មភាពសណ្ឋាគារដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយ និងស្ថិតក្នុងទីតាំងរួមជាមួយសណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

ឧទាហរណ៍ទី២÷ សហគ្រាសមួយប្រកបអាជីវកម្ម ទិញ-លក់កុំព្យូទ័រ កម្មវិធីកុំព្យូទ័រ ឧបករណ៍លេងហ្គេមទូរស័ព្ទដៃ ឧបករណ៍ទូរគមនាគមន៍ផ្សេងៗ វិទ្យុ ទូរទស្សន៍ ម៉ាស៊ីនចាក់និងថតស៊ីឌី ឌីវីឌី ឧបករណ៍បំពងសំឡេង ដែលអាជីវកម្មនេះស្ថិតនៅក្នុងចង្កោមសកម្មភាពអាជីវកម្ម "ទិញ-លក់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិក" តែមួយ ហើយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយ និងស្ថិតក្នុងទីតាំងប្រកបអាជីវកម្មតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៣- អ្នកជាប់ពន្ធដែលមានទីកន្លែងអាជីវកម្មជាគោលដើម ទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយនៅក្នុងរាជធានី-ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៤- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់នៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

## ប្រការ ៥.. កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល។

២- អ្នកជាប់ពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល។

៣- អ្នកជាប់ពន្ធធំ ត្រូវបង់÷

ក- ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៣ ០០០ ០០០ រៀល។

ខ- ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៥ ០០០ ០០០ រៀល ក្នុងករណីដែលមានផលរបរលើសពី ១០ ០០០ លានរៀល។

អ្នកជាប់ពន្ធដែលមានទីកន្លែងអាជីវកម្មជាគោលដើម ទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់អប្បបរមាសម្រាប់ប្រភេទអ្នកជាប់ពន្ធនីមួយៗនៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

## ប្រការ ៦.. កាលបរិច្ឆេទបង់ពន្ធ

ពន្ធប៉ាតង់ ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ ពន្ធប៉ាតង់ត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ។

អ្នកជាប់ពន្ធដែលចាប់ផ្ដើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែដើមឆ្នាំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប៉ុន្តែប្រសិនបើចាប់ផ្ដើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែចុងឆ្នាំ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធប៉ាតង់ពាក់កណ្ដាល។

## ប្រការ ៧.. ប័ណ្ណពន្ធប៉ាតង់

ប័ណ្ណពន្ធប៉ាតង់ មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណពន្ធប៉ាតង់តែប៉ុណ្ណោះ។ ករណីមានការផ្លាស់ប្ដូរទីកន្លែងទៅរាជធានី-ខេត្តផ្សេង ឬផ្លាស់ប្ដូរមុខរបរអាជីវកម្មថ្មី ត្រូវបង់ប្រាក់ពន្ធប៉ាតង់ថ្មីម្ដងទៀត។

ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវា អ្នកជាប់ពន្ធត្រូវមានប័ណ្ណពន្ធប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាទាំងនោះ។

អ្នកជាប់ពន្ធ ត្រូវមានកាតព្វកិច្ចដាក់តាំងបង្ហាញប័ណ្ណពន្ធប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។ ក្នុងករណីអ្នកជាប់ពន្ធមិនបានដាក់តាំងបង្ហាញប័ណ្ណពន្ធប៉ាតង់ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ ស្របតាមមាត្រា ១២៨ និងមាត្រា ១៣៣ នៃច្បាប់ស្ដីពីសារពើពន្ធ។

**ប្រការ ៨..	ការឈប់ ផ្អាក ឬផ្លាស់ប្តូរម្ចាស់អាជីវកម្ម**

១- សហគ្រាសដែលស្នើសុំឈប់ឬផ្អាកអាជីវកម្ម នៅក្នុងឆ្នាំជាប់ពន្ធណាមួយ÷

ក- តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពាក់កណ្តាល ប្រសិនបើដាក់ពាក្យសុំឈប់ ឬផ្អាកអាជីវកម្មនៅក្នុងអំឡុង ៦ខែដើមឆ្នាំនៃឆ្នាំចរន្ត។

ខ- តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពេញមួយឆ្នាំ ប្រសិនបើដាក់ពាក្យសុំឈប់ ឬផ្អាកអាជីវកម្មនៅក្នុងអំឡុង ៦ខែចុងឆ្នាំនៃឆ្នាំចរន្ត។

ប្រាក់ពន្ធប៉ាតង់ដែលបានបង់រួចហើយ មិនត្រូវបានបង្វិលសងវិញទេ។

២-ចំពោះអាជីវកម្មដែលផ្លាស់ប្តូរម្ចាស់ បើម្ចាស់ចាស់បានបង់ពន្ធប៉ាតង់ហើយ ម្ចាស់ថ្មីមិនបាច់បង់ពន្ធប៉ាតង់ជាថ្មីទៀតទេ ប្រសិនបើមានគ្រប់លក្ខណៈពីរខាងក្រោមនេះ÷

ក- មិនផ្លាស់ប្តូរសកម្មភាពអាជីវកម្ម។

ខ- ម្ចាស់ថ្មីជាឪពុក ម្តាយ ប្តី ប្រពន្ធ កូន ឬអ្នកស្នងស្របច្បាប់របស់ម្ចាស់អាជីវកម្មចាស់។

**ប្រការ ៩..	និរាករណ៍**

ប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០..	ការអនុវត្ត**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

| មាតិកា | ទំព័រ |
| --- | --- |
| តើពន្ធប៉ាតង់ជាអ្វី? | ១ |
| តើមូលដ្ឋានគិតពន្ធប៉ាតង់ជាអ្វី? | ១ |
| តើពន្ធប៉ាតង់ត្រូវគណនាយ៉ាងដូចម្តេច? | ១ |
| តើពន្ធប៉ាតង់ត្រូវបង់នៅពេលណា? | ២ |
| តើត្រូវបង់ពន្ធប៉ាតង់នៅទីកន្លែងណា? | ២ |
| ប្រសិនបើអ្នកជាប់ពន្ធផ្លាស់ប្តូរសកម្មភាពអាជីវកម្ម តើត្រូវបង់ពន្ធប៉ាតង់សម្រាប់សកម្មភាពអាជីវកម្មថ្មី ឬទេ? | ៣ |
| ប្រសិនបើអ្នកជាប់ពន្ធបន្ថែមសកម្មភាពអាជីវកម្មថ្មី តើត្រូវបង់ពន្ធប៉ាតង់សម្រាប់សកម្មភាពអាជីវកម្មថ្មី ឬទេ? | ៣ |
| ប្រសិនបើអ្នកជាប់ពន្ធផ្លាស់ប្តូរទីកន្លែង តើត្រូវបង់ពន្ធប៉ាតង់សម្រាប់ទីតាំងថ្មី ឬទេ? | ៣ |
| ប្រសិនបើសហគ្រាសមានសាខា ឬរោងជាងជំនួយ តើត្រូវបង់ពន្ធប៉ាតង់សម្រាប់សាខា ឬរោងជាងជំនួយដែរឬទេ? | ៣ |
| ប្រសិនបើសហគ្រាសត្រូវផ្លាស់ប្តូរម្ចាស់ តើត្រូវបង់ពន្ធប៉ាតង់ឡើងវិញដែរឬទេ? | ៤ |
| តើមានការដាក់ពិន័យ និងទោសទណ្ឌអ្វីខ្លះ ចំពោះការមិនគោរពតាមច្បាប់ពន្ធប៉ាតង់? | ៤ |
| សំណួរ | ៥ |
| អាសយដ្ឋានទំនាក់ទំនង | ៥ |
| តារាងកំណត់ប្រាក់ពន្ធប៉ាតង់ | ១១ |

## សំណួរ

ប្រសិនបើលោកអ្នកមានចម្ងល់ ឬសំណួរផ្សេងៗ ដែលពុំទាន់ឆ្លើយនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ សូមទាក់ទងមកកាន់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តណាមួយដែលក្រុមហ៊ុនបានចុះបញ្ជី។

## អាសយដ្ឋានទំនាក់ទំនង

### អគ្គនាយកដ្ឋានពន្ធដារ

៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥)
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (៨៥៥) ២៣ ៨៨៦ ៧០៨
សារអេឡិចត្រូនិក៖ info@tax.gov.kh

### នាយកដ្ឋាន សេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ

សារអេឡិចត្រូនិក៖ dtsta@tax.gov.kh

### នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ

សារអេឡិចត្រូនិក៖ dlls@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

សារអេឡិចត្រូនិក៖ dlt@tax.gov.kh

### សាខាពន្ធដារ ខណ្ឌឫស្សីកែវ

ផ្ទះលេខ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ russeykeo@tax.gov.kh

**សាខាពន្ធដារ ខណ្ឌដូនពេញ**

ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្ដាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ daunpenh@tax.gov.kh

**សាខាពន្ធដារ ខណ្ឌ៧មករា**

ផ្ទះលេខ២៥បេ ផ្លូវសម្ដេចប៉ាន(២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ 7makara@tax.gov.kh

**សាខាពន្ធដារ ខណ្ឌមានជ័យ**

អគារលេខ៣៨សេ ផ្លូវ៣៦១កែង៦៨២ សង្កាត់ច្បារអំពៅ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ meanchey@tax.gov.kh

**សាខាពន្ធដារ ខណ្ឌចំការមន**

ផ្ទះលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ chamkarmorn@tax.gov.kh

**សាខាពន្ធដារ ខណ្ឌទួលគោក**

ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានី ភ្នំពេញ

សារអេឡិចត្រូនិក៖ tuolkork@tax.gov.kh

**សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ**

ផ្ទះលេខ២៣៩ ផ្លូវលេខ២០០៧ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ dangkor@tax.gov.kh

**សាខាពន្ធដារ ខេត្តកណ្ដាល**

ផ្ទះលេខ១០៣ ផ្លូវលេខ១០៨ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល

សារអេឡិចត្រូនិក៖ kandal@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពង់ចាម**

ផ្ទលេខ៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម

សារអេឡិចត្រូនិក៖ kampongcham@tax.gov.kh

**សាខាពន្ធដារ ខេត្តបាត់ដំបង**

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

សារអេឡិចត្រូនិក៖ battambang@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រៃវែង**

ភូមិលេខ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

សារអេឡិចត្រូនិក៖ preyveng@tax.gov.kh

**សាខាពន្ធដារ ខេត្តសៀមរាប**

ផ្លូវជាតិលេខ៦ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប

សារអេឡិចត្រូនិក៖ siamreap@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពត**

ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

សារអេឡិចត្រូនិក៖ kampot@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រះសីហនុ**

ផ្លូវ២៨មិថុនា សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

សារអេឡិចត្រូនិ៖ preahsihanouk@tax.gov.kh

**សាខាពន្ធដារ ខេត្តកោះកុង**

ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

សារអេឡិចត្រូនិក៖ kohkong@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រះវិហារ**

ភូមិកណ្តាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

សារអេឡិចត្រូនិក៖ preahvihear@tax.gov.kh

**សាខាពន្ធដារ ខេត្តក្រចេះ**

ផ្ទះលេខ៧៣ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ

សារអេឡិចត្រូនិក៖ kratie@tax.gov.kh

**សាខាពន្ធដារ ខេត្តរតនៈគិរី**

ផ្លូវភូមិអូរកន្សែង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនៈគិរី

សារអេឡិចត្រូនិក៖ ratanakiri@tax.gov.kh

**សាខាពន្ធដារ ខេត្តមណ្ឌលគិរី**

ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី

សារអេឡិចត្រូនិក៖ mondulkiri@tax.gov.kh

**សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ**

ប្លុកU ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ
ខេត្តបន្ទាយមានជ័យ

សារអេឡិចត្រូនិក៖ banteaymeanchey@tax.gov.kh

**សាខាពន្ធដារ ខេត្តស្ទឹងត្រែង**

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

សារអេឡិចត្រូនិក៖ stoengtreng@tax.gov.kh

**សាខាពន្ធដារ ខេត្តកែប**

ផ្លូវ៣៣A ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប

សារអេឡិចត្រូនិក៖ kep@tax.gov.kh

**សាខាពន្ធដារ ខេត្តប៉ៃលិន**

ភូមិបឱនាវ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន

សារអេឡិចត្រូនិក៖ pailin@tax.gov.kh

**សាខាពន្ធដារ ខេត្តឧត្តរមានជ័យ**

ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

សារអេឡិចត្រូនិក៖ odormeanchey@tax.gov.kh